Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:52 AM Page 3

*បេន្នី វីដ្យូណូ*
(Benny Widyono)

# សាក្សីប្រវត្តិសាស្ត្រ

បកប្រែពីភាសាអង់គ្លេសដោយ
លោក ទូច សុពុទ្ធី  លោក ថុល ឌីណា
ពិនិត្យឡើងវិញដោយ
លោក វង្ស សុធារ៉ា
មើលកែដោយ
លោកស្រី ជា ប៊ុនណារី
អ្នកចាត់ចែងគម្រោង៖ លោក ម៉ែន ឈានរិទ្ធី
អ្នកសម្របសម្រួលខាងការបោះពុម្ពផ្សាយ៖ លោក យ៉ែម យឿន

*Dancing in Shadows*

Translated from English by Touch Soputhy and Thol Dina
Peer Reviewers: Vong Sotheara
Editor: Ms Chea Bunnary
Project Supervisor: Men Chean Rithy
Publishing Coordinator: Yem Yoeun

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:52 AM Page 4

រក្សាសិទ្ធិ គ.ស. ២០០៨ ដោយ រ៉ូមែន អែន លីតថលហ្វៀល ផាប់ប្លីស្ហឺ អាយអែនស៊ី ។
Copyright © 2008 by Rowman & Littlefield Publishers, Inc.

រក្សាសិទ្ធិក្នុងការបកប្រែ និងចេញជាភាសាខ្មែរ © គ.ស. ២០១១ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។
Copyright © 2011, Center for Khmer Studies for the Khmer translation.

រូបភាពក្របមុខដោយ ◢ Cover picture
ចន អ៊ីសាក (រក្សាសិទ្ធិ) គ.ស. ១៩៩៣ Copyright © 1993 John Isaac.

ការបកប្រែ និងការបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមជ្ឈមណ្ឌលខេមរសិក្សា ។
The publication of this book was supported by Center for Khmer Studies.

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-២៣-៥ ISBN-13: 978 - 99950 - 51 - 23 - 5

បោះពុម្ពនៅភ្នំពេញ **(Printed in Phnom Penh)**

# សារបណ្ណា

**រូបភាព** ...... ១០

**សេចក្តីផ្តើម** ...... ១២

*អារម្ភកថា* ...... ១២

*សេចក្តីផ្តើម* ...... ១៦

*បុព្វកថារបស់លោក ប៊ិន ឃៀរនិន* ...... ១៨

កំណត់ចំណាំជំពូកបុព្វកថារបស់លោក ប៊ិន ឃៀរនិន ...... ២៨

**ផ្នែកទី ១ ៖ និន្នាការទូទៅ ១៩៥២-១៩៩៣** ...... ៣១

**ជំពូកទី ១ ៖ នៅពេលដែលពិភពលោកចូលលុកលុយប្រទេសកម្ពុជា** ...... ៣៣

*នៅក្នុងបន្ទប់ទឹកនៅញូយ៉ក* ...... ៣៥

*ការលុកលុយរបស់ «អ៊ុនតាក់»* ...... ៤២

*យន្តការផ្ទៃក្នុងរបស់អ៊ុនតាក់* ...... ៤៣

កំណត់ចំណាំជំពូកទី១ ...... ៥០

**ជំពូកទី ២ ៖ ក្រឡេកមើលអតីតកាល** ...... ៥៦

*បីដំណាក់កាលនៃសោកនាដកម្មកម្ពុជា* ...... ៥៦

*កិច្ចព្រមព្រៀងក្រុងប៉ារីស: គុណវិបត្តិដំណោះស្រាយ* ...... ៦៥

កំណត់ចំណាំជំពូកទី២ ...... ៧០

**ជំពូកទី ៣ ៖ ភាពដឹកនាំនយោបាយដ៏ស្មុគស្មាញរបស់រដ្ឋាភិបាល** ...... ៧៦

*តើនរណាពិតជាទទួលខុសត្រូវនៅទីនេះ?* ...... ៧៦

*ការមកដល់របស់ខ្ញុំនៅសៀមរាប* ...... ៧៩

អិត កុប៉ារ៉ា ...... ៨៣

កំណត់ចំណាំជំពូកទី៣ ...... ៨៧

**ជំពូកទី ៤ ៖ យើងសម្លឹងគ្នា ហើយខ្ញុំព្រិចភ្នែក** ...... ៩០

*ព្រះអង្គម្ចាស់ជ្ជាទី ២* ...... ៩០

*ហេតុអ្វីខ្ញុំព្រិចភ្នែក* ...... ៩២

*ទេវកថានៃការគ្រប់គ្រង* ...... ៩៧

*ឧត្តមសេនីយ៍ ឡុង សុភាព ធ្វើសកម្មភាព* ...... ១០៥

កំណត់ចំណាំជំពូកទី៤ ...... ១០៧

**ជំពូកទី ៥ ៖ ខ្មែរក្រហមធ្វើឱ្យបរាជ័យដល់ការរំសាយទ័ព** ...... ១១២

*ការចាប់ផ្តើមនៃការរំសាយទ័ព* ...... ១១២

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:52 AM Page 6




*ឧប្បត្តិហេតុបង្គោលបុស្សី និងការរំសាយទ័ព* ..... ១១៤

*ស្ថានភាពអាក្រក់មុនល្អក្រោយ* ..... ១១៩

*ពិធីដប់សៀងដែលប្រារព្ធឡើងដោយខ្មែរក្រហម* ..... ១២២

*តើប្រជាជនកម្ពុជាគិតយ៉ាងដូចម្ដេចចំពោះខ្មែរក្រហម?* ..... ១២៩

**កំណត់ចំណាំជំពូកទី៤** ..... ១៣២

**ជំពូកទី ៦ ៖ ស្ថានភាពគ្រោតគ្រាតមុនការបោះឆ្នោត** ..... ១៣៦

*មានតែពលរដ្ឋ «កម្ពុជា» ទេដែលមានសិទ្ធិបោះឆ្នោត* ..... ១៣៦

*សម្ពន្ធអតីតកាលដ៏រន្ធត់* ..... ១៣៧

*អំពើហិង្សាមុនការបោះឆ្នោត* ..... ១៣៩

*តើនរណាជាអ្នកទទួលខុសត្រូវរឿងសន្តិសុខ?* ..... ១៤៦

**កំណត់ចំណាំជំពូកទី៦** ..... ១៤៩

**ជំពូកទី ៧ ៖ បោះឆ្នោតដើម្បីសន្តិភាពឬ?** ..... ១៥២

*ទីបំផុត បានទៅផ្ទះវិញហើយ* ..... ១៥២

*ការទទួលបានកិត្តិយសមកវិញ* ..... ១៥៦

*ឆ្ពោះទៅកាន់សង្គមពហុបក្ស* ..... ១៥៨

*ទីបញ្ចប់ដល់ថ្ងៃបោះឆ្នោត* ..... ១៦២

*តើជារដ្ឋប្រហាររដ្ឋធម្មនុញ្ញឬ?* ..... ១៦៧

*ការផ្ដាច់ខ្លួន* ..... ១៧១

*រដ្ឋាភិបាលក្បាលពីរ* ..... ១៧៣

**កំណត់ចំណាំជំពូកទី៧** ..... ១៧៦

**ផ្នែកទី ២ ៖ ប្រេសិតសហប្រជាជាតិម្នាក់នៅភ្នំពេញ ១៩៩៤-១៩៩៧** ..... ១៧៩

**ជំពូកទី ៨ ៖ ខ្វះតួសម្ដែង** ..... ១៨១

*គ្មានទាំងអំណាច និង មធ្យោបាយ* ..... ១៨១

*ការវិលត្រឡប់របស់អ្នករាជានិយម* ..... ១៨៧

*ការផ្លាស់ប្ដូររបស់រាជរដ្ឋាភិបាល* ..... ១៨៨

*ការដើរតួរបស់បរទេស* ..... ១៩៣

*គ្រាប់បែកទីមួយផ្ទុះឡើង* ..... ១៩៤

**កំណត់ចំណាំជំពូកទី៨** ..... ១៩៥

**ជំពូកទី ៩ ៖ ព្រះមហាក្សត្រគ្រងរាជ្យសម្បត្តិ តែមិនកាន់អំណាច** ..... ១៩៨

*លោក ហ៊ុន សែន* ..... ១៩៨

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread [illegible]chel.qxd 5/11/2011 9:52 AM Page 7




សម្តេចក្រុមព្រះរណឫទ្ធិ ........ ២០០

ភ្ញៀវកិត្តិយសម្នាក់ជាមួយនឹងនាយករដ្ឋមន្ត្រីពីររូប ........ ២០២

សវនាការមួយជាមួយព្រះមហាក្សត្រ ........ ២០៥

មហិច្ឆតារលាយក្លាយជាផេះផង់ ........ ២០៨

ជម្លោះចុងក្រោយតាមប៉ាកា ........ ២១១

ការលេចឡើងនៃបុរសខ្លាំងមួយរូប ........ ២១៤

លោករួម រិត នៅពីរ៉េណេ ........ ២១៦

**កំណាត់ចំណាំជំពូកទី៩ ........ ២១៩**

**ជំពូកទី ១០ ៖ ការប៉ុនប៉ងធ្វើរដ្ឋប្រហារសម្ងាត់មួយ ........ ២២២**

នរណាជាមេគំនិត? ........ ២២២

ចុងបញ្ចប់ខ្មែរក្រហមត្រូវនៅក្រៅច្បាប់ ........ ២២៧

សារទូរលេខរបស់លោក ហូឡូវេ ........ ២២៨

ការចាកចេញរបស់លោក សម រង្ស៊ី ........ ២២០

ត្រកូល នរោត្តមទីពីរដែលត្រូវចាកចេញ ........ ២៣៤

**កំណាត់ចំណាំជំពូកទី១០ ........ ២៤២**

**ជំពូកទី ១១ ៖ តើមានគំរូអាស៊ីណាមួយ សម្រាប់អភិវឌ្ឍន៍តាមមែនឬ? ........ ២៤៦**

ការបង្កើតសន្តិភាពក្រោយជម្លោះ ........ ២៤៦

ជាគំរូអភិវឌ្ឍន៍មួយនៅអាស៊ីមែនទេ? ........ ២៤៩

ការឆ្លើយតបរបស់ម្ចាស់ជំនួយ ........ ២៥១

ការរីកចម្រើនវិស័យឯកជនដែលគួរឲ្យកត់សម្គាល់ ........ ២៥៧

មានគ្រួសមួយដុំនៅក្នុងស្បែកជើងរបស់ខ្ញុំ ........ ២៦៣

**កំណាត់ចំណាំជំពូកទី១១ ........ ២៦៩**

**ជំពូកទី ១២ ៖ នាយករដ្ឋមន្ត្រីរាយ៉ង? ........ ២៧៤**

សេរីភាព ឬ ការឈ្លានពាន? ........ ២៧៤

កិច្ចប្រជុំសម្ងាត់ ........ ២៧៧

ព្រះអង្គម្ចាស់ រណឫទ្ធិ បង្កើតបញ្ហាក្តៅគគុក ........ ២៧៨

ការអញ្ជើញជាភ្ញៀវកិត្តិយសមកកាន់ក្រុងតាខ្មៅ ........ ២៨១

ខែមេសានៅទីក្រុងប៉ារីស ........ ២៨៧

ការអញ្ជើញជាភ្ញៀវកិត្តិយសមកកាន់វិថីសម្តេច ប៉ាន ........ ២៨៩

**កំណាត់ចំណាំជំពូកទី១២ ........ ២៩៦**

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:52 AM Page 8



**ជំពូកទី ១៣ ៖ ឆ្ពោះទៅរកទំនាស់ដ៏ស្រួចស្រាល់មួយ** .......... ២៩៨
*ការផ្តាច់ខ្លួនរបស់អៀង សារី* .......... ២៩៨
*ការធ្វើដំណើរជាលើកទីពីររបស់ខ្ញុំទៅកាន់ប៉ៃលិន* .......... ៣០០
*រដ្ឋាភិបាលចម្រុះឈានដល់ការបែកបាក់* .......... ៣០៤
*ការបែកបាក់ផ្ទៃក្នុងរបស់គណបក្សហ៊្វុនស៊ិនប៉ិច* .......... ៣០៦
*យុទ្ធសាស្ត្រដទៃទៀតរបស់ព្រះអង្គម្ចាស់រណឫទ្ធិ* .......... ៣០៧
*ដាក់រាជសារជាថ្មីម្តងទៀតហើយមែនទេ?* .......... ៣១០
*ការវាយប្រហារដោយគ្រាប់បែកដៃដ៏គួរឲ្យរន្ធត់* .......... ៣១២
*កិច្ចខិតខំប្រឹងប្រែងទូភាគីដែលឥតប្រយោជន៍* .......... ៣១៣
*ការនាំចូលអាវុធ«ខុសច្បាប់»របស់ព្រះអង្គម្ចាស់រណឫទ្ធិ* .......... ៣១៤
*កងវរសេនាតូចអង្គរក្ស* .......... ៣១៥
*កំណត់សម្គាល់ផ្ទាល់ខ្លួនមួយ* .......... ៣១៩
កំណត់ចំណាំជំពូកទី១៣ .......... ៣២២
**ជំពូកទី ១៤ ៖ ការបង្ហាញសាច់ដុំលើកចុងក្រោយ** .......... ៣២៦
*ថ្ងៃទី៥-៦ខែកក្កដា នៅទីក្រុងភ្នំពេញ* .......... ៣២៦
*ទស្សនៈរបស់រដ្ឋាភិបាល* .......... ៣៣០
*សាក្សីបរទេសធ្វើការនៅកម្ពុជា* .......... ៣៣២
*លទ្ធផលក្រោយការប្រយុទ្ធ* .......... ៣៣៣
*ប្រតិកម្មរបស់អន្តរជាតិ* .......... ៣៣៥
*សង្គ្រាមបានផ្លាស់ទៅនៅទីក្រុងញូយ៉ក* .......... ៣៣៨
*ស្ថិរភាពនៅចុងបញ្ចប់* .......... ៣៤២
កំណត់ចំណាំជំពូកទី១៤ .......... ៣៤៧
**អវសានកថា** .......... ៣៥២
កំណត់ចំណាំជំពូក អវសានកថា .......... ៣៦៦
**កាលប្បវត្តិសង្ខេប** .......... ៣៧០
*ឧបសម្ព័ន្ធ ទី១៖ ការដាក់ពង្រាយកងកម្លាំងរបស់អ៊ុនតាក់* .......... ៣៧៨
*ឧបសម្ព័ន្ធ ទី២៖ រាជរដ្ឋាភិបាលកម្ពុជា ខែវិច្ឆិកាឆ្នាំ១៩៩៣* .......... ៣៧៩
កន្ថនិទ្ទេស .......... ៣៨១
**លិបិក្រម** .......... ៣៨៩
*អំពីអ្នកនិពន្ធ* .......... ៤០២

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:52 AM Page 9

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 10



# រូបភាព


១.១ ជនរងគ្រោះដោយសារគ្រាប់មីនអង្គុយនៅលើកៅអីរុញ៖ទិដ្ឋភាពធម្មតាដែលគេឃើញមាននៅក្នុងសម័យអ៊ុនតាក់ ....................................................................................................... ៤១

១.២ មន្ត្រីអ៊ុនតាក់កំពុងភ្ជាប់ប្រដាប់បញ្ចាំងពន្លឺនៅលើស៊ីក្លូ....................................................... ៤៤

១.៣ ឧទ្ធម្ភាគចក្រ MI-26 ខ្នាតយក្សធ្វើនៅសហភាពសូវៀតបាននាំខ្ញុំ និងរថយន្តរបស់ខ្ញុំមកដល់ខេត្តសៀមរាបដោយជោគជ័យ ........................................................................................ ៤៥

៣.១ «មេដឹកនាំ» ពីររូបនៅសម័យអ៊ុនតាក់»លោកអាកាស៊ីប្រធានអ៊ុនតាក់និងសម្តេចនរោត្តមសីហនុប្រធាន SNC.................................................................................................... ៧៧

៤.១ លោកអាកាស៊ីធ្វើសេចក្តីថ្លែងការណ៍នៅក្នុងការប្រជុំប្រចាំខែរបស់ប្រធានសាខាខេត្តនៅក្រុងភ្នំពេញនៅខាងឆ្វេងដៃរបស់គាត់គឺលោក Gerard Porcell(ជីរាតប៉ូសែល)ប្រធានផ្នែករដ្ឋបាលស៊ីវិល.................... ៩៣

៤.២ ការស្តាប់វិទ្យុគឺជាការលំហែដ៏ពេញនិយមមួយនៅពាសពេញផ្ទៃប្រទេសកម្ពុជា........................... ១០៣

៤.៣ ក្រុមអប់រំផ្សព្វផ្សាយអ៊ុនតាក់បានធ្វើដំណើរតាមទូកទៅកាន់កោះមួយនៅប្រទេសកម្ពុជាដើម្បីផ្សព្វផ្សាយពីការបោះឆ្នោត................................................................................................ ១០៣

៥.១ កងកម្លាំងប្រដាប់អាវុធរបស់ប្រជាជនកម្ពុជា(CPAF)កំពុងកាត់រំសាយ........................................ ១១៥

៥.២ អ្នកអង្កេតការណ៍យោធារបស់អ៊ុនតាក់មកពីសហរដ្ឋអាមេរិកកំពុងប្រឡែងលេងជាមួយនឹងទារកកុលសម្ព័ន្ធ krung-Bra (គ្រុង-ព្រៅ)......................................................................... ១១៨

៦ .១ ទាហានខ្មែរក្រហមនៅក្នុងតំបន់កាន់កាប់របស់ក្រុមម្ខាងទៀត........................................ ១៤០

៧ .១ ប្រជាជនកម្ពុជាបានធ្វើមាតុភូមិនិវត្តន៍ពីជំរំជនភៀសខ្លួនក្នុងប្រទេសថៃ.................................... ១៥៣

៧.២ ប្រជាជនកម្ពុជាម្នាក់បានបង្ហាញកាតបោះឆ្នោតរបស់គាត់យ៉ាងមានមោទនភាពនៅពីមុខផ្ទាំងបដាផ្សព្វផ្សាយស្តីពីការបោះឆ្នោតរៀបចំឡើងដោយអ៊ុនតាក់................................................... ១៥៧

៧ .៣ រថយន្តរបស់អង្គការសហប្រជាជាតិបានធ្វើដំណើរឆ្លងកាត់ក្រោមបដាផ្សព្វផ្សាយពីការបោះឆ្នោតនៅក្នុងរាជធានីភ្នំពេញ................................................................................................. ១៥៩

៧.៤ ហ្វូងមនុស្សកំពុងឈរផ្តុំគ្នានៅក្បែរមណ្ឌលបោះឆ្នោតនៅក្នុងខេត្តព្រៃវែង................................... ១៦២

៧.៥ ស្ត្រីម្នាក់បានទទួលសន្លឹកឆ្នោតរបស់គាត់ពីមន្ត្រីរៀបចំការបោះឆ្នោតអ៊ុនតាក់................................ ១៦៣

៧.៦ សមាជិកមន្ត្រីរៀបចំការបោះឆ្នោតរបស់អង្គការសហប្រជាជាតិកំពុងរាប់សន្លឹកឆ្នោត ៗប្រជាជនកម្ពុជាពុំអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការរាប់សន្លឹកឆ្នោតទេ.................................................... ១៦៤

៨.១ ដំណើរកំសាន្តលក្ខណៈគ្រួសារនៅរាល់រសៀលថ្ងៃសៅរ៍បន្ទាប់ពីប្រទេសកម្ពុជាថ្មីមួយបានប្រសូតចេញពីការបោះឆ្នោត...................................................................................................... ១៨៥

៩.១ ការចូលសម្តែងសវនាការជាលើកដំបូងរបស់ខ្ញុំជាមួយនឹងព្រះមហាក្សត្រ.......................................... ១០៧

១១.១ សំបុត្រគំរាមកំហែងដល់ជីវិតពីសំណាក់ពួកខ្មែរក្រហមបានមកដល់ការិយាល័យខ្ញុំតាមរយៈអ្នកនាំសារខ្មែរក្រហម................................................................................................. ២៥៣

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 11



១៣.១ សម្តេចហ៊ុនសែន(ខាងឆ្វេង)កំពុងជួបជាមួយលោកអៀងសារី នៅក្រុងប៉ៃលិន............................**៣០២**
១៤.១ សម្តេចហ៊ុនសែននាយករដ្ឋមន្ត្រីប្រទេសកម្ពុជានៅខាងឆ្វេងមានប្រសាសន៍ជាមួយនិងសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ អតីតនាយករដ្ឋមន្ត្រីនិងជាប្រធានសភាថ្មីនៅក្នុងការប្រារព្ធទិវាសិទ្ធិមនុស្សជាសកលនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨.......................................................................................................**៣៤៥**

# ផែនទី

១.១ ប្រទេសកម្ពុជា នៅពេលដែលខ្ញុំមកដល់នៅខែមីនាឆ្នាំ១៩៩២.........................................................**៣៧**
៣.១ ផែនទីរដ្ឋបាលខេត្តសៀមរាបបង្ហាញពីស្ថិតិប្រជាជនតាមស្រុកនីមួយៗ............................................**៨១**
៤.១ ការធ្វើដំណើររបស់កងកម្លាំងអ៊ុនតាក់ដើម្បីទៅបោះទីតាំងបណ្តោះអាសន្ននិងរៀបចំការកាត់រំសាយកងទ័ព.......................................................................................................................**៩៦**
៥.១ ការធ្វើដំណើររបស់កងកម្លាំងអ៊ុនតាក់ដើម្បីទៅជួយរៀបចំការបោះឆ្នោតបន្ទាប់ពីការកាត់រំសាយកងទ័ពបរាជ័យ.......................................................................................................................**១១៧**
៧.១ ការធ្វើមាតុភូមិនិវត្តន៍នៅកម្ពុជា គោលដៅចុងក្រោយរបស់អ្នកធ្វើមាតុភូមិនិវត្តន៍...........................**១៥៥**
៧.២ លទ្ធផលនៃការបោះឆ្នោតរៀបចំឡើងដោយអ៊ុនតាក់÷ ការបែងចែកអសនៈនៅក្នុងសភា...............**១៦៥**

# តារាង

៥.១ កម្លាំងនិងគ្រឿងសព្វាវុធរបស់កងកម្លាំងប្រដាប់អាវុធទាំងបួនក្រុមរាយការណ៍ដល់អង្គការសហប្រជាជាតិ.......................................................................................................................**១១៣**
៧.១ លទ្ធផលនៃការបោះឆ្នោតឆ្នាំ១៩៩៣ដែលគណបក្សនីមួយៗបានទទួល...........................................**១៧១**

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 12



# អារម្ភកថា

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តមខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលឯកឧត្តមបានផ្តល់កិត្តិយសក្នុងការសរសេរអារម្ភកថាដល់សៀវភៅបកប្រែជាភាសាខ្មែររបស់ខ្ញុំនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកប្រធានមជ្ឈមណ្ឌលខេមរ-សិក្សាផងដែរគឺលោកស្រីបណ្ឌិត ល័រស៍ ឌឺ មេនីល (Lois De Menil) ដែលបានជួយជម្រុញលើកទឹកចិត្តដល់ស្នាដៃរបស់ ខ្ញុំដោយធ្វើការស្នើសុំនិងរៀបចំឲ្យមានការបកប្រែសៀវភៅរបស់ខ្ញុំជាភាសាខ្មែរ។ ម្យ៉ាងវិញទៀត ខ្ញុំក៏មិនអាចបំភ្លេចនូវគុណូបការៈរបស់លោក អូលីវីយេ ប៊ែរនីញ៉េរ (Olivier Bernier) អនុប្រធានមជ្ឈមណ្ឌលខេមរសិក្សាផងដែរ។ ប្រសិនបើពុំមានគាត់ទេការបកប្រែសៀវភៅនេះនឹងពុំអាចលេចចេញជារូបរាងបានឡើយ ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់លោក ម៉ៃឃើល ស៊ូលីវ៉ាន់ (Michael Sullivan) នាយកមជ្ឈមណ្ឌលខេមរសិក្សាដែលបានខ្នះខ្នែងបញ្ចូលគម្រោងបកប្រែនេះទៅក្នុងបេសកកម្មផ្សព្វផ្សាយចំណេះដឹងរបស់មជ្ឈមណ្ឌលខេមរសិក្សាដល់បញ្ញវន្តនិងយុវជនខ្មែរ ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថារាល់កំហុសខុសឆ្គងទាំងឡាយដែលមាននៅក្នុងសៀវភៅនេះ ខ្ញុំគឺជាអ្នកទទួលខុសត្រូវតែម្នាក់គត់ ។

សៀវភៅនេះផ្តោតជាសំខាន់ទៅលើព្រឹត្តិការណ៍កើតមានឡើងនៅក្នុងអំឡុងពេល៥ឆ្នាំដែលខ្ញុំមានវត្តមាននៅក្នុងប្រទេសកម្ពុជា ក្នុងនាមជាមន្ត្រីរបស់អង្គការសហប្រជាជាតិ។ នៅក្នុងអំឡុងពេលនោះដំបូងឡើយខ្ញុំបានបំរើការជានាយកប្រចាំខេត្តសៀមរាបនៅក្នុងសម័យអ៊ុនតាក់ពីចន្លោះឆ្នាំ១៩៩២-១៩៩៣ដើម្បីបំពេញបេសកកម្មអនុវត្តនូវកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលក្នុងនោះពួកយើងក៏ត្រូវធ្វើយ៉ាងណាបង្កើតឲ្យមានការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាផងដែរ។ បន្ទាប់ពីនោះមក ខ្ញុំក៏បានធ្វើការងារជាអ្នកតំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជាអំឡុងឆ្នាំ ១៩៩៤-១៩៩៧ ។

គឺចាប់តាំងពីពេលនោះមក នយោបាយប្រទេសកម្ពុជាបានវិវត្តទៅជាមានស្ថិរភាពសារជាថ្មី និងទទួលបានការទុកចិត្តពីសហគមន៍ប្រទេសផ្តល់ជំនួយដែលខិតខំប្រឹងប្រែងបន្តផ្តល់ជំនួយសំខាន់ៗ កាន់តែច្រើនឡើងៗដល់ប្រទេសកម្ពុជា។ ប្រាក់ជំនួយបូកផ្សំនឹងការវិនិយោគទុនទាំងអ្នករកស៊ីក្នុងស្រុកនិងបរទេស និងចំនួនភ្ញៀវទេសចរដែលបានមកទស្សនាប្រាសាទអង្គរវត្តកាន់តែច្រើនឡើងៗផងនោះ បានធ្វើឲ្យប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយនេះ ពោលគឺកើនឡើងចាប់ពី៧%ដល់១៣%។ ជាការពិតណាស់សព្វថ្ងៃនេះ ប្រទេសកម្ពុជាត្រូវគេចាត់ថ្នាក់នៅក្នុងក្រុមប្រទេសអាស៊ីដែលមានកំណើនសេដ្ឋកិច្ចខ្ពស់រួចបាត់ទៅហើយ ។ប្រជាជនកម្ពុជាជាង៥០%សព្វថ្ងៃបានចាប់កំណើតបន្ទាប់ពីពួកខ្មែរក្រហមត្រូវកងកម្លាំងយោធាវៀតណាមនិងកងកម្លាំងរណសិរ្សសង្គ្រោះជាតិកម្ពុជាបណ្តេញចេញពីអំណាចនៅក្នុងឆ្នាំ១៩៧៩។

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 13



ការកាត់ទោសនៅថ្ងៃទី២៦ខែកក្កដាឆ្នាំ២០១០របស់កាំង ហ្គេចអ៊ាវ ហៅឌុចអតីតមេគុក «ស២១» ដែលជាមណ្ឌលឃុំឃាំងសំខាន់បំផុតរបស់ខ្មែរក្រហមពីបទឧក្រិដ្ឋកម្មមនុស្សជាតិនិងបទរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ដែលបានធ្វើឲ្យមានការចាប់អារម្មណ៍សារជាថ្មីម្តងទៀតពីសំណាក់អ្នកសារព័ត៌មានអន្តរជាតិមកលើប្រទេសកម្ពុជា (យ៉ាងហោចណាស់ក្នុងមួយរយៈពេលខ្លីដែរ)។ សាលក្រមរបស់សាលាកាត់ក្តីខ្មែរក្រហមដែលបានទទួលការឧបត្ថម្ភគាំទ្រពីអង្គការសហប្រជាជាតិគឺមានសារៈសំខាន់ណាស់ ។ បន្ទាប់ពីពួកខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចអស់រយៈពេល៣០ឆ្នាំមកនេះគឺជាលើកដំបូងហើយ ដែល មន្ត្រីសំខាន់របស់ខ្មែរក្រហមរូបនេះត្រូវគេនាំយកមកកាត់ក្តីឲ្យទទួលខុសត្រូវលើបទឧក្រិដ្ឋដ៏ឃោរឃៅដែលខ្លួនបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។ នៅឆ្នាំក្រោយនេះ គេនឹងដំណើរការកាត់ក្តីសំណុំរឿងករណី០០២បន្តទៀតដែលក្នុងនោះមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលនៅរស់រានមានជីវិតចំនួនបួនរូបទៀតនឹងត្រូវគេយកមកកាត់ទោសផងដែរ ក្នុងនោះរួមមានលោក នួន ជា លោកអៀង សារី លោកស្រី អៀង ធារិទ្ធនិងលោកខៀវ សំផន ។

ប៉ុន្តែយើងអាចមានចម្ងល់ថាតើមូលហេតុអ្វីបានជាការកាត់ក្តីនេះបានពន្យារពេលរហូតដល់៣០ឆ្នាំ? ជាការពិត ជារឿយៗ នៅក្នុងសារព័ត៌មានអន្តរជាតិ សកម្មភាពរបស់បរទេសក្នុងការបង្កសោកនាដកម្មដល់ប្រជាជនកម្ពុជាមិនត្រូវបានគេយកមកលាតត្រដាង ឬ យកមកបរិយាយជាសាធារណៈទេ។ មិនត្រឹមតែប៉ុណ្ណោះ ឥឡូវនេះ ពួកគេស្ទើរតែទាំងអស់គ្នាបានថ្លែងថាការបណ្តេញរបបខ្មែរក្រហមចេញដោយកងទ័ពវៀតណាមនៅខែមករាឆ្នាំ១៩៧៩ បានបង្កឲ្យមាន«សង្គ្រាមស៊ីវិល១០ឆ្នាំ»បន្តទៅទៀត។ ប៉ុន្តែ ដូចដែលខ្ញុំបានលើកបង្ហាញនៅក្នុងជំពូកទី២ អញ្ចឹង អ្វីដែលពួកគេខកខានមិនបានរាយការណ៍នោះគឺសង្គ្រាមស៊ីវិលនេះភាគច្រើនមិនមែនកើតឡើងដោយសារបញ្ហាដែលកើតមាននៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែកើតឡើងនៅឯក្រុងញូយ៉កដែលមានចម្ងាយ ឆ្ងាយពីប្រទេសកម្ពុជារាប់ពាន់គីឡូម៉ែត្រឯណោះទៅវិញ។ ដោយមានការនាំមុខពីសម្ទាក់សហរដ្ឋអាមេរិកនិងប្រទេសចិនរយៈពេល ១១ ឆ្នាំ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ អង្គការសហប្រជាជាតិនៅតែបន្តទទួលស្គាល់របបខ្មែរក្រហមថាជារដ្ឋាភិបាលស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដដែល បើទោះបីជាពេលនោះរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានគ្រប់គ្រងលើផ្ទៃប្រទេសស្ទើរតែ៩០%ទៅហើយក្តី ។

នៅក្នុងស្ថានភាពបែបនេះ សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលជារដ្ឋាភិបាលពិតប្រាកដនៅក្រុងភ្នំពេញត្រូវគេដាក់ឲ្យនៅឯកោ គ្មាននរណារាប់រកសូម្បីតែក្នុងផ្នែកសេដ្ឋកិច្ចឬនយោបាយ។ ចំណែកឯពួកខ្មែរក្រហមនិងក្រុមបក្សសម្ព័ន្ធរបស់ពួកគេគឺគណបក្ស FUNCINPEC (ហ៊្វុនស៊ិនប៉ិច) និងគណបក្ស KPNLF វិញបែរជាបានទទួលការបំពាក់អាវុធនិងការពង្រឹងសមត្ថភាពនៅតាមព្រំដែនថៃពីសំណាក់ប្រទេសចិននិងប្រទេសលោកខាងលិចទៅវិញ។ ទង្វើបែបនេះហើយគឺជាការជម្រុញឲ្យមាននូវអ្វីដែលពួកគេហៅថា«សង្គ្រាមស៊ីវិល»ប្រឆាំងទៅនឹងរដ្ឋាភិបាលក្រុងភ្នំពេញ។

បន្ទាប់ពីសង្គ្រាមត្រជាក់បានបញ្ចប់ទៅ ភាគីទាំងអស់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស នៅខែតុលាឆ្នាំ១៩៩១ ក្នុងគោលបំណងស្វែងរកនូវសុខសន្តិភាពមួយជូនដល់ប្រទេសកម្ពុជា។ ប៉ុន្តែជាសំណាងអាក្រក់ ដោយសារនៅមានបញ្ហាជាច្រើនបានបន្សល់ទុកនៅពុំទាន់បាន

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 14



ដោះស្រាយចប់កាលពីទសវត្សន៍មុននោះ កិច្ចព្រមព្រៀងនេះបានធ្វើឲ្យមានកំហុសយ៉ាងហោចណាស់ក៏ពីរដែរ ។ ទី១តាមកិច្ចព្រមព្រៀង ពួកខ្មែរក្រហមត្រូវតែមានតួនាទីស្របច្បាប់ក្នុងឆាកនយោបាយនៅក្នុងប្រទេសកម្ពុជា ។ ដូច្នេះ ពួកគេត្រូវតែទទួលបាននូវការផ្សះផ្សាដោយពុំតម្រូវឲ្យមានការកាត់ទោសកំហុសអ្វីដែលពួកគេបានប្រព្រឹត្តកន្លងមកទេ ។ ចំនុចទីពីរ កិច្ចព្រមព្រៀងបានបន្ថយនូវឋានៈរបស់រដ្ឋកម្ពុជា (ពីអតីតកាលមានឈ្មោះថាសាធារណរដ្ឋប្រជាមានិតកម្ពុជា) ដែលជារដ្ឋាភិបាលគ្រប់គ្រងប្រទេសកម្ពុជាអស់រយៈពេល១១ឆ្នាំមកហើយនោះ ឲ្យមកនៅត្រឹមតែជារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលមួយក្នុងចំណោមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលទាំង៤ដែលមាននៅពេលនោះតែប៉ុណ្ណោះ។

ដូចដែលខ្ញុំបានរៀបរាប់នៅក្នុងផ្នែកទី១នៃសៀវភៅនេះអញ្ចឹង ដោយសារតែកំហុសនៅក្នុងកិច្ចព្រមព្រៀង ដែលអ៊ុនតាក់មានតួនាទីក្នុងការចុះអនុវត្តកិច្ចព្រមព្រៀងនេះបានទទួលការបរាជ័យតាំងពីដំណាក់កាលដំបូងដោយសារតែនៅមានភាគីជម្លោះជាច្រើនគ្រប់គ្រងតំបន់ផ្សេងៗពីគ្នា ការមានសេចក្ដីសង្ឃឹមហួសពីការពិតជាក់ស្ដែង ការខ្វះបទពិសោធន៍ និងភាពរឹងរូសរបស់អង្គការសហប្រជាជាតិ និងការដែលមានអ្នកនយោបាយជាច្រើនពោរពេញទៅដោយភាពមន្ទិលសង្ស័យមិនទុកចិត្តគ្នាទៅវិញទៅមក ។ ខ្ញុំលើកឧទាហរណ៍មួយមកនិយាយឲ្យកាន់តែច្បាស់ទៀតទាក់ទងនឹង អ៊ុនតាក់ៗ ជាការពិត ពួកគេត្រូវមានតួនាទីត្រួតពិនិត្យគ្រប់គ្រងលើប្រទេសកម្ពុជាជាប្រចាំ ប៉ុន្តែការងារនេះគឺជាការងារមួយដ៏លំបាកបំផុតសម្រាប់ពួកគេដោយសារតែពួកគេជាអ្នកដែលស្ទើរតែមិនដឹងអ្វីសោះពីប្រទេសនេះ ។ ម្យ៉ាងវិញទៀត ពួកគេក៏មានបទពិសោធន៍តិចតួច ជាមួយនឹងការងាររបៀបនេះ ហើយនិងមិនសូវមានអ្នកចេះភាសាខ្មែរផងដែរ ។ ដោយដឹងថាអ៊ុនតាក់គ្រាន់តែជាខ្លាក្រដាសនោះ ពួកខ្មែរក្រហមបានរំលោភរាល់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយនៅតែរួចខ្លួន បន្ទាប់ពីអ៊ុនតាក់បានចាកចេញ ។ ដូច្នេះហើយ ពួកគេបានទទួលនូវឱកាសជាលើកទីពីរក្នុងការបង្កការរំខានដល់ប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជាដែលទើបតែនឹងប្រសូតចេញពីការបោះឆ្នោតៗ លើសពីនេះទៀត ការយកខ្មែរក្រហមមកកាត់ទោសក៏ពួកមហាអំណាចនៅក្រុងញូយ៉កពុំដែលបានគិតគូរទាល់តែសោះឡើយៗ

នៅផ្នែកទី២ នៃសៀវភៅនេះ បានរៀបរាប់នូវរឿងរ៉ាវដែលខ្ញុំបានឃើញផ្ទាល់ភ្នែកនៅក្នុងអំឡុងឆ្នាំ១៩៩៤-១៩៩៧ នៅពេលដែលខ្ញុំបំពេញការងារជាអ្នកតំណាងនយោបាយរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជាៗ ខ្ញុំបានមើលឃើញដោយផ្ទាល់នូវការប្រេះឆារបស់រាជរដ្ឋាភិបាលកម្ពុជាដែលទើបតែប្រសូតចេញពីការបោះឆ្នោតថ្មីៗហើយនិងភាពតានតឹងដែលកាន់តែកើនខ្លាំងឡើងៗរវាងនាយករដ្ឋមន្ត្រីទាំងពីររូបជាពិសេសភាពតានតឹងនេះបានឡើងដល់កម្រិតកំពូលរហូតដល់មានការប្រយុទ្ធគ្នានៅថ្ងៃទី៥-៧កក្កដាឆ្នាំ១៩៩៧ដែលជុតបន្ថែមដោយការគម្រាមកំហែងជាបន្តពីការកកើតឡើងវិញនូវឧទ្ទាមខ្មែរក្រហមៗ

ចុងបញ្ចប់ នៅខែមិថុនា ឆ្នាំ១៩៩៧ ដោយសារមានការជម្រុញយ៉ាងខ្លាំងពីលោកថូម៉ាស់ ហែម៉ាប៊ឺគ (Thomas Hammarberg) អ្នកតំណាងពិសេសខាងផ្នែកសិទ្ធិមនុស្សនៅកម្ពុជារបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោកនាយករដ្ឋមន្ត្រីទាំងពីររូបក៏បានចុះហត្ថលេខាលើលិខិតមួយស្នើសុំជំនួយពីអង្គការសហប្រជាជាតិក្នុងការយកមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមមកកាត់ទោសៗ ជាចុងក្រោយ ការ

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 15



ចរចាដែលចំណាយពេលយ៉ាងយូរលើការស្នើសុំនេះ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលប្រទេសកម្ពុជាក៏បានហុចផលជាផ្លែផ្កាដោយបង្កើតឲ្យមានសាលាកាត់ក្តីខ្មែរក្រហម ។

ខ្ញុំនៅតែធ្វើដំណើរមកកាន់ប្រទេសកម្ពុជាពីពីរទៅបីដងក្នុងមួយឆ្នាំដើម្បីបំពេញតួនាទីជាទីប្រឹក្សាដល់មូលនិធិសមធម៌ឯកជនមួយដែលមានឈ្មោះថា លីអូប៉ាត ខេមបូឌា (Leopard Cambodia) និងជាក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលខេមរសិក្សា ។ សព្វថ្ងៃនេះ ប្រទេសកម្ពុជាបានទាក់ទាញអារម្មណ៍ និងបេះដូងរបស់ខ្ញុំកាន់តែច្រើនឡើងថែមទៀត នៅពេលដែលខ្ញុំបានឃើញផ្លូវដែលក្មេងៗជំនាន់ក្រោយកំពុងតែដើរឆ្ពោះទៅរកអនាគតមួយដែលគេមិនអាចស្រមើស្រមៃដល់កាលពីប៉ុន្មានឆ្នាំមុននោះ។ យុវជនកម្ពុជាកំពុងតែមមាញឹកក្នុងការគិតគូរអំពីមុខរបរវិជ្ជាជីវៈរបស់ខ្លួន និងធ្វើយ៉ាងណាទើបធ្វើឲ្យគេប្រលងជាប់ ប៉ុន្តែពួកគេមានការយកចិត្តទុកដាក់តិចតួចលើការកាត់ទោសមេដឹកនាំខ្មែរក្រហម។ ដូច្នេះហើយ បន្ទាប់ពីការពន្យារពេល៣០ឆ្នាំ ទីបំផុតខណៈពេលដែលសាលាក្តីខ្មែរក្រហមបានចាប់ផ្តើមផ្តល់នូវយុត្តិធម៌មួយបែបដែលបានដាក់ទោសទណ្ឌដល់ជនឧក្រិដ្ឋ សាលាក្តីនេះប្រហែលជាធ្វើឲ្យប្រជាជនកម្ពុជាភាគច្រើនពុំបានទទួលនូវយុត្តិធម៌មួយដែលអាចជួយសម្រាលជីវភាពនិងស្ថានភាពផ្លូវចិត្តដល់ជនរងគ្រោះនោះទេ ។ ជាការពិតណាស់ យុត្តិធម៌របៀបនេះក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ព្រោះវាជាយុត្តិធម៌មួយដែល ជួយជម្រុញឲ្យមានការស្វែងរកការពិត ការអត់ឱន ការអត់ធ្មត់ និងការផ្សះផ្សាតាមរយៈមធ្យោបាយមួយដែលមានប្រសិទ្ធភាពនិងការចំណាយតិចជាងសាលាកាត់ក្តីសព្វថ្ងៃដែលសម្បូរទៅដោយបញ្ហាចម្រូងចម្រាសនិងចំណាយអស់ថវិកាជាច្រើន ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានលើកនៅខាងលើនេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានដើរតួនាទីដ៏គួរឲ្យកោតសរសើរ។ ក្រៅពីផ្តល់នូវការសិក្សាស្រាវជ្រាវសំខាន់ៗដល់សាលាក្តីខ្មែរក្រហមហើយ នៅពេលថ្មីៗនេះ មជ្ឈមណ្ឌលនេះក៏បានបោះពុម្ពសៀវភៅមេរៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលនឹងត្រូវយកទៅដាក់បង្រៀនអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅតាមសាលាទូទាំងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ដោយមានកិច្ចសហប្រតិបត្តិការជាមួយនិងក្រសួងអប់រំ យុវជននិងកីឡា មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំដាក់ផ្ទាំងពាក្យស្លោកអប់រំឲ្យមានការចងចាំនូវមេរៀនដ៏ជូរចត់ដែលបានមកពីរបបប្រល័យពូជសាសន៍នៅតាមវិទ្យាល័យចំនួន១៧០០ក្នុងប្រទេសកម្ពុជាផងដែរ ។

ដូច្នេះ ដើម្បីចូលរួមចំណែកក្នុងការងារនេះ ខ្ញុំសង្ឃឹមថាការបោះពុម្ពសៀវភៅរបស់ខ្ញុំជាភាសាខ្មែរដោយមជ្ឈមណ្ឌលខេមរសិក្សានឹងក្លាយទៅជាវិភាគទានមួយទៀតដើម្បីជួយអប់រំដល់យុវជននិងបញ្ញវន្តកម្ពុជាអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។

**បេន្នី វីដ្យូណូ** (Benny Widyono)

ញូយ៉ក ខែមករា ឆ្នាំ ២០១១

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 16



# សេចក្តីផ្តើម

សម្លឹងមើលទៅអតីតកាលវិញក្នុងសម័យអន្តរាគមន៍របស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជាដែលគេតែងឲ្យឈ្មោះថា**«សម័យអ៊ុនតាក់»**នោះ ពេលនោះខ្ញុំបាទបានទទួលតំណែងជាប្រធានក្រុមលេខាធិការនៃភាគីរដ្ឋកម្ពុជាក្នុង**«ឧត្តមក្រុមប្រឹក្សាជាតិ»**ឬអេសអិនស៊ី ។ ក្រោយការបោះឆ្នោតពោរ-ពេញដោយភាពចម្រូងចម្រាសនាឆ្នាំ១៩៩៣មក យើងបានឃើញនូវភាពគម្ពីរនិយមក៏ដូចជាភាពលំអៀងរបស់មនុស្សមួយចំនួនដែលគេបានសន្មតជា**«អ្នកមានឯកទេសផ្នែកប្រទេសកម្ពុជា»** ជា**«នយោបាយវិទូ»**ឬជា**«អ្នកអព្យាក្រឹត្យ»** នៅតែបន្តជះឥទ្ធិពលរហូតដល់បច្ចុប្បន្ននេះ។

ដំបូងបង្អស់គេតែងនិយាយពីកម្រិតហិង្សា**«យ៉ាងខ្ពស់»**នៅក្នុងរយៈពេលបោះឆ្នោតឆ្នាំ១៩៩៣ ហើយគេពន្យល់ថា**«មកពីប្រទេសកម្ពុជាមិនដែលមានលទ្ធិប្រជាធិបតេយ្យ»**តែនៅពេលដែលមានប្រជាជនជាង៩០ភាគរយចូលរួមបោះឆ្នោត គេទូងស្គរអួតពីជោគជ័យរបស់អ៊ុនតាក់ដែល**«ការពារប្រជាជនមិនឲ្យខ្លាចការគំរាមកំហែង»**។ លុះដល់ប្រធានអ៊ុនតាក់គឺឯកឧត្តម អាកាស៊ីទទួលបរាជ័យនៅបូស្នៀគេចោទថានោះមកពីគ្មានការសហការរបស់អាជ្ញាធរនៅនឹងកន្លែងទៅវិញ។

នៅពេលដែលមានការផ្ទុះសង្គ្រាមក្នុងទីក្រុងភ្នំពេញនាថ្ងៃ៥-៦មិថុនា១៩៩៧ ពួកអ្នកគម្ពីរនិយមក៏បានលើកពីក្បួនរបស់ពួកគេដែលថា**«រកស៊ីជាមួយពួកកុំម្មុយនីស្តគឺពិតជាមិនបានសុខជាដាច់ខាត»**។ ហេតុនេះ ថ្វីត្បិតតែសម្តេចហ៊ុន សែនគឺជាមនុស្សដែលពីពេលមុនត្រូវគេចាត់ទុកថាជាមនុស្សដែលអនុវត្តកំណែទម្រង់យ៉ាងមោះមុត និងជាស្ថាបនិកកិច្ចព្រមព្រៀងទីក្រុងប៉ារីសយ៉ាងណាក្តី ក៏ត្រូវអ្នកទាំងនោះទម្លាក់កំហុសទាំងអស់ទៅលើរូបលោក ក្នុងខណៈពេលដែលពួកគេមិនបានយល់អ្វីសោះពីតថភាពនៅក្នុងកម្ពុជានាពេលនោះ។

តាមពិតទៅ ការបោះឆ្នោតឆ្នាំ១៩៩៣ដែលពួកគម្ពីរនិយមបស្ចិមប្រទេសសម្លឹងមើលថាជាការប្រកួតប្រជែងរវាងគណបក្សនយោបាយនានាដូចដែលក្បួនគម្ពីរស្តីពីការបោះឆ្នោតបានរៀបរាប់នោះពួកគេបានភ្លេចមើលឃើញថានៅកម្ពុជានេះមិនមែនគ្រាន់តែជាការបោះឆ្នោតដណ្តើមអំណាចរវាងគណបក្សនយោបាយនានាប៉ុណ្ណោះទេ តែគឺជាការប្រកួតប្រជែងរវាងកម្លាំងពីរក្រុម(រដ្ឋកម្ពុជានិងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលមានកម្លាំងខ្មែរក្រហមជាឆ្អឹងខ្នង)ដែលមានរចនាសម្ព័ន្ធយោធារដ្ឋបាលនិងនយោបាយពេញលេញ ហើយដែលបានប្រយុទ្ធស្លាប់រស់ជាមួយគ្នាអស់រយៈកាលមួយសតវត្សមកហើយនោះ។ នៅក្នុងស្ថានភាពដ៏តឹងតែងពេលនោះ ភាពមិនទុកចិត្តគ្នាបានដក់នៅជាប្រចាំក្នុងគ្រប់ភាគី ជ័យជំនះរបស់ភាគីមួយអាចនឹងបង្កការរលត់រលាយភាគីមួយទៀត។ ហេតុនេះហើយភាពមិនទុកចិត្តនៅពេលនោះបានបង្កឡើងជា**ស្ថានភាពហិង្សាមួយដើម្បីដណ្តើមរស់** ដែលអ្នកមិនយល់ពីស្ថានភាពកម្ពុជាពេលនោះចាត់ទុកជាសញ្ញា**កង្វះប្រពៃណីប្រជាធិបតេយ្យ**ទៅវិញ។

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread-Rachel.qxd 5/11/2011 9:53 AM Page 17



*ជោគជ័យរបស់អ៊ុនតាក់ដែលគេបានអួតយ៉ាងខ្ចរខ្ចារមិនបានបន្តទទួលបាននៅក្នុងប្រទេសបូស្នៀនាឆ្នាំ១៩៩៥ទេ ហើយលោក អាកាស៊ី ដដែល បានទទួលខុសត្រូវលើភាពបរាជ័យនៃបេសកកម្មស្វែងរកសន្តិភាពរបស់អង្គការសហប្រជាជាតិៗ ក្នុងពេលនោះដែរ គេបិទភ្នែកមិនព្រមទទួលយកសច្ចភាពមួយនៃកត្តា«**ជោគជ័យ**»របស់អង្គការសហប្រជាជាតិនៅកម្ពុជា ដែលជា**កិច្ចសហការរបស់គណបក្សកាន់អំណាច** គឺគណបក្សប្រជាជនកម្ពុជាដែលកត្តានេះមិនបានកើតមានឡើងនៅតំបន់បូស្នៀ-ហែសេកូវីណា* (Bosnia-Herzegovina)*នោះឡើយៗ*

*ការចោទព្រឹត្តិការណ៍ផ្ទុះអាវុធថ្ងៃ៥-៦មិថុនា១៩៩៧ថាជារដ្ឋប្រហាររបស់គណបក្សប្រជាជនក៏បានរត់តាមឡូស៊ិចនៃគម្ពីរនិយមដដែលនេះដែរៗ អ្វីដែលគេមិនបានយល់មិនបានដឹងឬក៏បិទភ្នែកមិនព្រមមើលវិវត្តន៍នៃហេតុការណ៍នោះ គឺជាយុទ្ធសាស្ត្ររបស់អ្នកនយោបាយស្ទើរភ្លើងមួយចំនួននៅក្នុងគណបក្សហ៊្វុនស៊ិនប៉ិចដែលចាប់ផ្តើមពីយុទ្ធសាស្ត្រ**«តុល្យភាពកម្លាំង»**នៅក្រោមដំបូលរដ្ឋាភិបាលតែមួយក្នុងតំបន់រដ្ឋបាលតែមួយទៅជាយុទ្ធសាស្ត្រ**«ស្វាអង្គុយលើភ្នំមើលខ្លាពីរខាំគ្នា»**ពោលគឺបម្រើបម្រាស់កម្លាំងខ្មែរក្រហមដើម្បីផ្តួលកម្លាំងរបស់អតីត**រដ្ឋកម្ពុជា** ៗគេអាចស្មានបានថាបើសិនជានៅពេលនោះកម្លាំងរបស់អតីតរដ្ឋកម្ពុជាចាញ់សង្គ្រាមសភាពការណ៍កម្ពុជាប្រហែលជាវិវត្តតាមទិសផ្សេងឆ្ងាយណាស់ព្រោះថាពួកខ្មែរក្រហមពិតជានឹងមិនព្រមដើរតួនៅពីក្រោយឆាកទៀតឡើយៗ*

*រឿងរ៉ាវទាំងនេះពិតមែនតែមិនមែនជាអំណះអំណាងរបស់លោកបេន្នី វីដ្យូណូ* (Benny Widyono) *ក្តី ក៏ប៉ុន្តែការរៀបរាប់របស់លោកនឹងអាចឲ្យគេឃើញច្បាស់នូវចន្លាយខ្សែចំណងដ៏ស្មុគស្មាញនៃបញ្ហាកម្ពុជា ៗ លោកបានត្រួសត្រាយក្នុងភាពសាមញ្ញតែច្បាស់លាស់ និងជាខ្សែសង្វាក់នូវអ្វីដែលបានកើតឡើងនាពេលនោះ ហើយសៀវភៅនេះអាចចាត់ទុកថាជាកំណត់ត្រាប្រវត្តិសាស្ត្រមួយប្រកបដោយភាពសត្យានុម័តនិងអាចទុកជាសៀវភៅមេរៀនមួយរបស់កងកម្លាំងរក្សាសន្តិភាពអន្តរជាតិនិងរបស់យន្តការស្វែងរកដំណោះស្រាយជម្លោះនៅក្នុងប្រទេសមួយ ៗ*

*ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងជួយអោយប្រវត្តិវិទូនិងកូនខ្មែរដែលមិនបានតាមដានសភាពការណ៍នយោបាយកម្ពុជាក្នុងពេលនោះ ក៏ដូចជាកូនខ្មែរជំនាន់ក្រោយៗទៀតបានយល់ពីប្រវត្តិសាស្ត្ររបស់កម្ពុជានិងអាចដកពិសោធន៍ពីទំព័រដ៏ខ្មៅនៃប្រវត្តិសាស្ត្រប្រទេសនេះដើម្បីចៀសអោយផុតពីការវិលត្រឡប់វិញនៃបទពិសោធន៍ដ៏ជូរចត់ដែលបានបំផ្លាញមនុស្សមួយស្រករឲ្យធ្លាក់ក្នុងហាយនភាព ៗ*

**ខៀវ កាញារីទ្ធ**

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 18



# បុព្វកថារបស់លោក បិន យៀរណិន

ព្រះវិហារសាសនាឥស្លាមន័រអាលឥសាន (Noor Al-Ihsan) លាបពណ៌សនៅភាគខាងជើងរាជធានីភ្នំពេញគឺជាអាគារមួយក្នុងចំណោមអាគារចំណាស់ជាងគេនៅរាជធានីប្រទេសកម្ពុជា។ នៅពេលទីក្រុង(គេសន្មតថាកសាងឡើងក្នុងឆ្នាំ១៨៣៤) បានប្រារព្ធខួបលើកទី៥៥ នាឆ្នាំ១៩៨៤ មានអាគារបន្តិចបន្តួចតែប៉ុណ្ណោះ ដែលមានអាយុកាលមុនសតវត្សទី១៩។ សញ្ញាជាអក្សរអារ៉ាប់និងខ្មែរនៅលើខ្លោងទ្វារចូលរបស់ព្រះវិហារដ៏ចំណាស់នេះបានបញ្ជាក់ពីកាលបរិច្ឆេទនៃការកសាងព្រះវិហារនេះ គឺនៅឆ្នាំ១៨១៣។ កាលបរិច្ឆេទនេះគឺក្រោយតែប៉ុន្មានឆ្នាំប៉ុណ្ណោះ បន្ទាប់ពីព្រះបរមរាជវាំងខ្មែរបានផ្លាស់ប្តូរទីតាំងមកពីក្រុងឧដុង្គអតីតរាជធានីចាស់ដែលនៅខាងលើដែនទន្លេ ទៅតាំងនៅក្រុងភ្នំពេញវិញ(ភាគខាងត្បូងនៃក្រុងឧដុង្គ)។ ក្រុងភ្នំពេញនៅពេលនោះមានប្រជាជនរស់នៅរួចជាស្រេចទៅហើយ។ ក្នុងចំណោមប្រជាជនទាំងនោះគឺមានប្រជាជនមួយក្រុមបានបង្កើតសហគមន៍មួយដែលមានឈ្មោះថាសហគមន៍ចាម។ តាមពិតទៅ ពួកគេគឺជាជនភៀសខ្លួនពីតំបន់ក្រោមដែនទន្លេ (នៅក្នុងប្រទេសវៀត-ណាមដែលជាប្រទេសជិតខាងជាប់ជាមួយកម្ពុជាសព្វថ្ងៃ) ដោយសារសង្គ្រាមស៊ីវិលមួយនៅសតវត្សទី១៨។ គួរឲ្យសោកស្តាយ កន្លែងប្រវត្តិសាស្ត្រដ៏សំខាន់ដែលជនជាតិចាមបានបង្កើតឡើងក្នុងឆ្នាំ១៨១៣ នៅរាជធានី(ទំនើប)របស់ប្រទេសកម្ពុជា ឥឡូវនេះ ត្រូវបានគេកំទេចខ្ទេចខ្ទីអស់ហើយ។ សព្វថ្ងៃនេះគ្មានអ្វីបន្សល់ជាដានពីព្រះវិហារន័រអាលឥសាននោះទៀតទេ។ ព្រះវិហារដ៏ចំណាស់ដែលមានឈ្មោះជាភាសាអារ៉ាប់ប្រែមកថា «ពន្លឺនៃសេចក្តីករុណា» ត្រូវគេយកយានយន្តប៊ុលដូហ្សែរមកឈូសកំទេចចោលនៅក្នុងទសវត្សរ៍ឆ្នាំ៩០ដើម្បីកសាងសំណង់ថ្មីក្លឹផ្អែកតាមស្ថាបត្យកម្មរបស់ពួកមជ្ឈិមបូព៌ា ក្រោមជំនួយឧបត្ថម្ភពីក្រុមជនជាតិគុយវ៉ែតនូវទឹកប្រាក់ចំនួន៧០.០០០ដុល្លាសហរដ្ឋអាមេរិក ក្នុងគោលបំណងលើកស្ទួយឲ្យមានការគោរពជំនឿឥស្លាមដូចគ្នាជាសកលក្នុងរាជាណាចក្រពុទ្ធសាសនា។

សូម្បីតែរបបប្រល័យពូជសាសន៍ប៉ុល ពត ក៏ទុកព្រះវិហារចាមជាប្រវត្តិសាស្ត្រនេះនៅដដែលដែរ។ ប៉ុន្តែការរក្សាទុកព្រះវិហារនេះមិនមែនដោយសារពួកគេមានការគោរពចំពោះសាសនាឥស្លាមនៅប្រទេសកម្ពុជានោះទេ។ នៅពេលដែលខ្ញុំបានមកទស្សនាជាដំបូងនៅព្រះវិហារន័រអាលឥសានក្នុងខែកក្កដាឆ្នាំ១៩៨០ សាសនិកជនឥស្លាមនៅក្នុងប្រទេសកម្ពុជាទើបតែចាប់ផ្តើមមានសភាពធូរស្បើយខ្លះៗពីការធ្វើទុក្ខបុកម្នេញនៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានសម្លាប់សាសនិកជនឥស្លាម១ភាគ៣ ឬប្រហែលជា ១០០.០០០នាក់ក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩។ ប៉ុន្តែ គួរឲ្យភ្ញាក់ផ្អើលណាស់ដែលប៉ុល ពតនៅតែអាចមានសិទ្ធិទទួលបានអាសនៈរបស់ប្រទេសកម្ពុជានៅក្នុងអង្គការសហប្រជាជាតិ ដោយសារគេគិតថា«បញ្ហាកម្ពុជា»គឺការឈ្លានពានរបស់វៀតណាមមិនមែនរបបប្រល័យពូជសាសន៍ដែលគេបានបញ្ឈប់ហើយនោះទេ។ នៅក្នុងប្រទេសកម្ពុជារដ្ឋាភិបាលថ្មីដែលគាំទ្រ

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 19



*ដោយវៀតណាមមិនមានការទទួលស្គាល់ពីក្រុងញូយ៉កនោះ បានប្រកាសថាប្រជាជនកម្ពុជាទាំងអស់បានទទួលរងនូវការធ្វើទុក្ខបុកម្នេញពីរបបប្រល័យពូជសាសន៍ ហើយក៏បានព្យាយាមបង្ហាញឲ្យគេមើលឃើញពីជោគវាសនាដ៏កំសត់របស់ជនជាតិភាគតិចដូចជាជនជាតិចាមជាដើម ប៉ុន្តែ ផ្ទុយទៅវិញអ្នកប្រាជ្ញខាងច្បាប់នៅតែមិនយកចិត្តទុកដាក់លើរឿងនេះទេ ។*

*ចូលមកដល់ឆ្នាំ២០០៧ យើងមានការលំបាកណាស់ក្នុងការគិតស្រមៃថាតើជនរងគ្រោះកម្ពុជាដែលនៅរស់(រួមទាំងជនជាតិចាមផងនោះ)ក្រោកឡើងប្រឆាំងនឹងអ្វីៗ នៅក្នុងអំឡុងឆ្នាំ១៩៨០ និង១៩៨១ មានតែប្រទេសកាន់សាសនាឥស្លាមចំនួនប្រាំមួយប៉ុណ្ណោះ នៅក្នុងចំណោមប្រទេសកាន់សាសនាឥស្លាមទូទាំងពិភពលោក បានបោះឆ្នោតប្រឆាំងនឹងរបបប៉ុល ពត ដែលទាមទារចង់រក្សាទុកអាសនៈកម្ពុជាសម្រាប់ខ្លួននៅអង្គការសហប្រជាជាតិៗ ប្រទេសទាំងនោះរួមមានប្រទេសអាហ្វហ្គានីស្ថាន ប្រទេសអាល់ហ្សេរី ប្រទេសឆាត ប្រទេសលីប្យ៉ា ប្រទេសស៊េរី និងប្រទេសហ្យេមែនខាងត្បូងៗ ចំណែកឯរដ្ឋឥស្លាមឬរដ្ឋអារ៉ាប់៦ទៀតពោលគឺរដ្ឋអ៊ីរ៉ង់ អ៊ីរ៉ាក់ ជ័រដាន់ លីបាណង់ ម៉ាលី និងទុយនីស៊ីបានធ្វើអនុបវាទមិនបោះឆ្នោតលើបញ្ហានេះទេ នេះប្រហែលដោយសារពួកគេមានភាពស្ទាក់ស្ទើរក្នុងការទទួលស្គាល់ស្របច្បាប់ចំពោះរបបដែលដួលរលំរួចទៅហើយ (ដោយមិនបាច់និយាយដល់អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលរបបនេះបានធ្វើនោះទេ)ៗ ប៉ុន្តែ មានប្រទេសកាន់សាសនាឥស្លាមមិនតិចជាង២១ទេ ដែលបានចូលជាសម្ព័ន្ធមិត្តជាមួយនឹងប្រទេសចិន សហរដ្ឋអាមេរិក និងប្រទេសអឺរ៉ុបផ្សេងទៀត(លើកលែងប្រទេសបារាំង ដែលពេលនោះបានធ្វើអនុបវាទ) ក្នុងការអនុញ្ញាតឲ្យអ្នកការទូតរបបខ្មែរក្រហមក្លាយទៅជាអ្នកតំណាងឲ្យជនរងគ្រោះដែលបង្កឡើងដោយរបបពួកគេទៅវិញៗ អ្នកដែលបោះឆ្នោតគាំទ្រការសម្រេចនេះរួមទាំងប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី (ជាសមាជិករបស់សមាគមអាស៊ាន) ប្រទេសបារ៉ែន បង់ក្លាដេស ដេបូទី អេហ្ស៊ីប គុយវ៉ែត ម៉ាលដៃម៉ូរីតា នៀម៉ូរ៉ូកូ នៃជឺ នៃជីរៀ អូម៉ង់ ប៉ាគីស្ថាន ហ្គាតាសូឌី អារ៉ាប់ប៊ី សេនេហ្គាល់ ស៊ូដង់ សូម៉ាលី ទួគីនិងសហរដ្ឋអារ៉ាប់អេមីរីតៗ[1]*

*នៅក្នុងបរិបទនេះហើយ ដែលជនបរទេសពីរនាក់បានមកសួរសុខទុក្ខអ្នករស់រានមានជីវិតជនជាតិចាមនិងចូលធ្វើការគោរពនៅក្នុងព្រះវិហារនូរ៍អាលឥសានៗ ពេលដែលខ្ញុំដើរចូលទៅក្នុងព្រះវិហារនៅថ្ងៃនោះ (ជាអំឡុងពេលពាក់កណ្តាលទសវត្សរ៍ឆ្នាំ៨០) ខ្ញុំបានឃើញពួកគេអង្គុយពែនភ្នែនលើកន្ទេលក្រាលនៅលើកម្រាលឥដ្ឋអាគារប្រវត្តិសាស្ត្រនោះ ជជែកជាមួយនឹងហាគីមមេដឹកនាំសហគមន៍ចាមនិងព្រឹទ្ធាចារ្យដទៃទៀតៗ ប្រាកដណាស់ អ្នករាយការណ៍ជនជាតិឥណ្ឌូនេស៊ីទាំងពីរនាក់នឹងបង្កើតនូវព្រឹត្តិការណ៍អ្វីមួយមិនខានឡើយៗ ប្រសិនបើយើងគិតថាសកម្មភាពរបស់ពួកគេគ្រាន់តែជាការចុះមកជួយសម្រាលដល់ការឈឺចាប់ខ្លោចផ្សារបស់ជនរងគ្រោះជនជាតិចាមក្នុងរយៈពេលខ្លី យើងក៏គួរតែគិតថាសកម្មភាពដដែលនេះក៏បានបង្ហាញពីការបញ្ចប់ភាពឯកោពីសំណាក់អន្តរជាតិផងដែរៗ តាមពិតទៅវត្តមានរបស់អ្នកសារព័ត៌មានល្បីល្បាញពីប្រទេសដែលមានសាសនិកជនឥស្លាមច្រើនជាងគេនៅលើពិភពលោកបានធ្វើឲ្យសម្រេចនូវទំនាក់ទំនងការទូតស្ងាត់ស្ងៀមដ៏តូចមួយដែរៗ អ្នកយកព័ត៌មានជនជាតិឥណ្ឌូនេស៊ីទាំងពីរនាក់គឺជាអ្នកនិពន្ធដ៏ឆ្នើមរបស់សារព័ត៌មានយ៉ាកាតាដ៏ល្បីល្បាញៗ លោកហ្វីគ្រី ជូហ្វ្រីអ្នកកាន់សាសនាឥស្លាមជាតិកំណើតជ្វាគឺជានិពន្ធនាយករងនៃទស្សនាវដ្តីប្រចាំសប្តាហ៍ថិមប៉ូ*

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 20



និង លោក សាបាមស្យាគៀន ជាជនជាតិបាតាក(Batak) កាន់សាសនាគ្រិស្តមកពីស៊ូម៉ាត្រាគឺជាអ្នកយកព័ត៌មានដ៏មានកេរ្តិ៍ឈ្មោះរបស់សារព័ត៌មានប្រចាំថ្ងៃ មានឈ្មោះថាស៊ីណាហារាប៉ាន់ (Sinar Hrapan)។ ជាងម្ភៃប្រាំឆ្នាំក្រោយមក ហាគីម អាលី ប៊ិនមូសេបានរំលឹកអំពីសំនួររបស់អ្នកទាំងពីរទាក់ទងនឹងរបបប៉ុល ពត ទាក់ទងនឹងរបៀបដែលខ្មែរក្រហមធ្វើទុក្ខបុកម្នេញចំពោះប្រជាជន និងទាក់ទងនឹងស្ថានភាពរបស់ព្រះវិហារឥស្លាមនៅក្រោយរបបខ្មែរក្រហម ។[២] បន្ទាប់ពីត្រឡប់មកកាន់ក្រុងយ៉ាកាតា លោក សាបាមស្យាគៀនបានធ្វើការរៀបរាប់អំពីទិដ្ឋភាពរបស់ប្រទេសកម្ពុជានៅក្នុងអត្ថបទសារព័ត៌-មានរបស់ស៊ីណា ហារាប៉ាន់ក្រោមចំណងជើងថា«មធ្យោបាយដោះស្រាយៈស្បៀងអាហារ សាសនា និងវប្បធម៌(នៅពេលណាដែលសន្តិភាពបានលេចឡើង)» ។[៣]

ការចុះមកធ្វើទស្សនកិច្ចយ៉ាងសាមញ្ញរបស់ជនជាតិឥណ្ឌូនេស៊ីមកកាន់ប្រទេសកម្ពុជា និងរបាយ-ការណ៍បន្តបន្ទាប់របស់ពួកគេទាក់ទងនឹងស្ថានភាពនៅទីនោះ បានជួយចាប់ផ្តើមធ្វើឲ្យមានការផ្លាស់ប្តូរគោលនយោបាយរដ្ឋការក្រុងយ៉ាកាតាបន្តិចម្តងៗ ដែលត្រូវបានគេបើកកកាយនៅទសវត្សក្រោយៗមកទៀត។ ការផ្លាស់ប្តូរគោលនយោបាយនេះបានជួយឲ្យប្រទេសឥណ្ឌូនេស៊ី ដើរតួនាទីយ៉ាងសំខាន់ក្នុងកា-រដោះស្រាយជម្លោះរបស់កម្ពុជានៅចុងទសវត្សរ៍ឆ្នាំ៨០។ កិច្ចការទូតក្រៅផ្លូវការរបស់អ្នកសារព័ត៌មានទាំងពីរក៏ជាគំរូមួយសម្រាប់ ជនរួមជាតិរបស់ពួកគេគឺលោក បេន្នី វីដ្យូណូ ដែលជាអ្នកនិពន្ធសៀវភៅនៅក្នុងដៃរបស់អស់លោកអ្នកផងដែរ។ គំរូនេះហើយដែលបានជួយឲ្យគាត់អាចធ្វើការចូលរួមចំណែកយ៉ាងឯករាជ្យដល់អនាគតរបស់ប្រទេសកម្ពុជានាទសវត្សរ៍ឆ្នាំ៩០ ។ តួនាទីប្រទេសឥណ្ឌូនេស៊ីនៅក្នុងការស្វែងរកដំណោះស្រាយសម្រាប់ការប្រឈមមុខដាក់គ្នាទាក់ទងនឹងប្រទេសកម្ពុជានៅក្នុងទសវត្សទី៨០ បានផ្តល់នូវទស្សនីយភាពមួយសម្រាប់ការនិពន្ធសៀវភៅនេះ ហើយថែមទាំងបានប្រាប់ឲ្យយើងដឹងនូវកិច្ចការរបស់គាត់ក្នុងនាមជាមន្ត្រីរដ្ឋាភិបាលដែលធ្វើការលើឆាកអន្តរជាតិ និងក្នុងនាមជាមន្ត្រីរបស់អង្គការសហប្រជាជាតិ តាមរយៈជីវប្រវត្តិរបស់គាត់ ជាអ្នកមានជំនាញខាងអាស៊ីអាគ្នេយ៍។

រហូតដល់ការដួលរលំរបបផ្តាច់ការរបស់ឯកឧត្តម ស៊ូហាតូ នៅក្នុងឆ្នាំ១៩៩៨ រាល់អ្នកសារព័ត៌មានជាតិឥណ្ឌូនេស៊ីទាំងអស់មិនថាមាននិន្នាការអ្វីទេ គឺត្រូវតែហែលឆ្លងកាត់របបមួយដែលគេមើលឃើញភាគច្រើនថាជារបបឧក្រិដ្ឋកម្ម។ អំឡុងទសវត្សរ៍ឆ្នាំ១៩៦៥ និង១៩៦៦ កងទ័ពរបស់ស៊ូហាតូបានដណ្តើមអំណាចនៅក្នុងព្រឹត្តិការណ៍កាប់សម្លាប់ជនកុំមុយនីស្តដែលជាប់ការសង្ស័យចំនួនជាង៥០០.០០០នាក់ ។ នៅពេលលោក ហ្វីគ្រី ជូហ្វ្រី និងលោកសាបាមស្យាគៀនបានមកទស្សនាប្រទេសកម្ពុជានាទសវត្សឆ្នាំ៨០ កងទ័ពរបស់លោកស៊ូហាតូនៅតែកំពុងបន្តសម្លាប់ជនស្លូតត្រង់ទីម័រខាងកើតដែលប្រឆាំងទៅនឹងការបង្ខំឲ្យពួកគេភ្ជាប់ទឹកដីរបស់ខ្លួនទៅនឹងប្រទេសឥណ្ឌូនេស៊ី ។ គោលនយោបាយរបស់រដ្ឋាភិបាលក្រុងយ៉ាកាតា ក៏ដាក់សម្ពាធមកលើប្រទេសកម្ពុជាឲ្យនៅឯកោ ហើយគាំទ្រពួកខ្មែរក្រហមដែរ។ប៉ុន្តែប្រទេសឥណ្ឌូនេស៊ីមិនមែនជាប្រទេសដែលចុះញ៉មនឹងរបបលោកស៊ូហាតូនោះទេ។ ភាពសម្បូរបែបខាងផ្នែកវប្បធម៌រួមទាំង៧០០ភាសា ដែលប្រើប្រាស់ដោយប្រជាជនច្រើនជាងគេរស់នៅលើប្រជុំកោះចំនួន៦ពាន់នោះបានធ្វើឲ្យសាធារណរដ្ឋមួយនេះក្លាយទៅជាសង្គមមួយដ៏ធំ មានជាតិសាសន៍រស់នៅច្រើនប្រកបទៅដោយអក្សរសិល្ប៍ និងប្រពៃណីយ៉ាងសម្បូរបែប ទាក់ទងទៅនឹងការប្រូបាច់បញ្ចូលគ្នា

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 21



ខាងសាសនា និងការព្រមព្រៀងស្រុះស្រួលគ្នា ។[៤] វប្បធម៌ទំនើបរបស់ឥណ្ឌូនេស៊ីក៏បានជម្រុញឲ្យមានអ្នកសារព័ត៌មានអង់អាចជាច្រើនដែលអ្នកខ្លះរហូតដល់ទទួលរងនូវគ្រោះថ្នាក់ពីអ្វីដែលពួកគេបានធ្វើទៀតផង ប៉ុន្តែ ទង្វើទាំងនោះជានិច្ចកាល បានជួយកែប្រែសង្គមជាច្រើន ។ ដូចជាសកម្មភាពដែលស្ថាប័នសារព័ត៌មានទាំងពីរបានបញ្ជូនអ្នករាយការណ៍ទាំងពីររូបមកកាន់ប្រទេសកម្ពុជាដ៏ឯកោនៅឆ្នាំ១៩៨០អញ្ចឹងៗ ពីរឆ្នាំក្រោយមក របបស៊ូហាតូបានហាមឃាត់ការផ្សព្វផ្សាយរបស់ទស្សនាវដ្តីប្រចាំសប្តាហ៍ថិមប៉ូរបស់លោក ហ្គីត្រី ដូហ្ស៊ី និងផ្អាកអាជ្ញាប័ណ្ណមិនឲ្យទស្សនាវដ្តីនេះបោះពុម្ព ប៉ុន្តែក្រោយមកហាក់បីដូចជាមានការបន្ធូរបន្ថយខ្លះ រហូតដល់ឆ្នាំ១៩៩៤ ទើបសម្រេចលែងផ្តល់អាជ្ញាប័ណ្ណឲ្យតែម្តងៗ នៅឆ្នាំ១៩៨៦ រដ្ឋាភិបាលក្រុងយ៉ាកាតាក៏បានហាមឃាត់ការផ្សាយសារព័ត៌មានស៊ីណា ហារាប៉ាន់របស់លោក សាបាមស្យាគៀនផងដែរៗ ប៉ុន្តែសារព័ត៌មានទាំងពីរនេះបានបង្កើតឡើងវិញភ្លាមៗដោយប្រើឈ្មោះថ្មី ឬក៏ទម្រង់មួយថ្មីទៀត ។[៥] ពីឆ្នាំ ១៩៨៣ ដល់ឆ្នាំ ១៩៩១ លោក សាបាមបានធ្វើការជានិពន្ធនាយកស្ថាបនិកនៃសារព័ត៌មានយ៉ាកាតាប៉ុស្ត៍ ។ ក្រោយមក លោកស៊ូហាតូក៏បានតែងតាំងគាត់ឲ្យទៅធ្វើជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសអូស្ត្រាលី ដាក់ន្ទៃងដែលគាត់បានធ្វើឲ្យក្រុមអ្នកសារព័ត៌មាននៅក្នុងស្រុកមានភាពរីករាយ ដោយគាត់បានហៅពួកគេយ៉ាងស្និទ្ធស្នាលថា«មនុស្សល្ងង់»នៅក្នុងសន្និសីទសារព័ត៌មានលើកដំបូងរបស់គាត់ៗ

ដំណើរទស្សនកិច្ចជាលក្ខណៈឯកជនរបស់ជនជាតិឥណ្ឌូនេស៊ីទាំងពីរមកកាន់ប្រទេសកម្ពុជានៅឆ្នាំ១៩៨០ គឺជាការនាំមកនូវអ្វីដែលថ្មីនៅក្នុងប្រទេសដែលទទួលរងនូវវិបត្តិសេដ្ឋកិច្ច និងវិនាសកម្មនៅឡើយ ហើយពេលនោះត្រូវពឹងពាក់ទៅលើជំនួយពីវៀតណាម និងសូវៀតថែមទៀតដើម្បីស្តារប្រទេសឡើងវិញៗ ប៉ុន្តែការវិវត្តទៅរកស្ថានការណ៍ថ្មីមួយទៀតក៏កំពុងតែចាប់ផ្តើមកើតឡើងផងដែរៗ ពីរបីខែមុននោះ គឺនៅក្នុងខែមីនាឆ្នាំ១៩៨០ លោក ស៊ូហាតូបានជួបនឹងនាយករដ្ឋមន្ត្រីម៉ាឡេស៊ីនៅក្រុងកោនតន់ប្រទេសម៉ាឡេស៊ី ហើយអ្នកទាំងពីរបានសម្រេចបង្កើតនូវ«គោលការណ៍កោនតន់»ៗ មេដឹកនាំឥណ្ឌូនេស៊ីនិងម៉ាឡេស៊ីបានបង្ហាញនូវកង្វល់ទាក់ទងនឹងតួនាទីរបស់សហភាពសូវៀតនៅក្នុងប្រទេសកម្ពុជាដែលមានប្រទេសវៀតណាមជាសម្ព័ន្ធមិត្ត ប៉ុន្តែ ពួកគេក៏បានមានកង្វល់ដូចគ្នានេះដែរចំពោះតួនាទីរបស់ប្រទេសចិនផងដែរៗ ព្រឹត្តិបត្រសេដ្ឋកិច្ចអាស៊ីចុងបូព៌ា(The FarEastern Economic Review)បានរាយការណ៍ថា ប្រទេសក្នុងតំបន់ភាគច្រើនមានគំនិតដូចគ្នាថា៖ «ដូចដែលគេគិតជាទូទៅអញ្ចឹង ប្រទេសវៀតណាមនឹងដកកងទ័ពចេញ ប្រសិនបើពុំមានជំនួយពីសហភាពសូវៀត ដើម្បីបន្តការឈ្លានពានរបស់ខ្លួនតទៅទៀត និងប្រសិនបើមានការធានាអះអាងពីប្រទេសចិនថា ចិននឹងមិនរំលោកចូលមកប្រទេសកម្ពុជា បន្ទាប់ពីការដកទ័ពវៀតណាមនោះ »ៗ[៦] បើនិយាយឲ្យស្រួលស្តាប់រដ្ឋការក្រុងហាណូយមានការព្រួយបារម្ភសមហេតុផលមួយចំនួនដែលប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ក៏មើលឃើញដូចគ្នាផងដែរៗ ជាឧទាហរណ៍ទាល់តែឆ្នាំ១៩៩០ ទើបប្រទេសឥណ្ឌូនេស៊ីបានចាប់ផ្តើមទំនាក់ទំនងការទូតឡើងវិញជាមួយនឹងប្រទេសចិនបន្ទាប់ពីផ្តាច់ទំនាក់ទំនងគ្នាអស់រយៈពេល២៥ឆ្នាំមកៗ ការព្រួយបារម្ភរបស់ប្រទេសនៅអាស៊ីអាគ្នេយ៍ត្រូវបានគេលើកយកមកពិភាក្សានៅក្នុងកិច្ចចរចាជាច្រើនៗ មេបញ្ជាការកងទ័ពរបស់ឥណ្ឌូនេស៊ីគឺលោក បេន្នី មួដានី (Benny Murdani) បានធ្វើដំណើរ

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 22



ជាសម្ងាត់ទៅកាន់ក្រុងហាណូយក្នុងឆ្នាំ១៩៨០ និង ឆ្នាំ១៩៨២ ដើម្បីព្យាយាមធ្វើការសម្រុះសម្រួលជម្លោះក្នុងប្រទេសកម្ពុជា ។[៧]

នៅឆ្នាំ១៩៨៣ រដ្ឋមន្ត្រីការបរទេសថ្មីរបស់ប្រទេសអូស្ត្រាលីគឺលោកបៀល ហេឌិន (Bill Hayden) បានធ្វើការកំណត់បញ្ហាពីរដែលទាក់ទងនឹងជម្លោះកម្ពុជា៖ការគំរាមកំហែងពីការវិលត្រឡប់មកកាន់អំណាចវិញរបស់របបខ្មែរក្រហម និងតម្រូវការចាំបាច់ក្នុងការឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជា។ លោក ហេឌិន សង្ឃឹមថានឹងជួយសម្របសម្រួលឲ្យមានការពិភាក្សានៅក្នុងតំបន់តាមការជួយជម្រុញពីប្រទេសឥណ្ឌូនេស៊ី។ រដ្ឋការយ៉ាកាតាបានដាក់អនុសាសន៍ឲ្យប្រទេសអូស្ត្រាលីផ្តល់ជំនួយដល់រដ្ឋការក្រុងហាណូយ។ បន្ទាប់មកនៅចុងឆ្នាំ១៩៨៣ ប្រទេសឥណ្ឌូនេស៊ីបានចាប់ផ្តើមនូវអ្វីដែលអ្នកអង្កេតការប្រទេសអូស្ត្រាលីម្នាក់បានហៅថាជា «កិច្ចការចែចូវៀតណាមដ៏គួរឲ្យចាប់អារម្មណ៍» (a fascinating coat-trailing exercise with Vietnam) ។[៨] នៅខែកុម្ភៈ ឆ្នាំ១៩៨៤ បន្ទាប់ពីលោកមេបញ្ជាការកងទ័ពឥណ្ឌូនេស៊ីបានសម្រេចចិត្តថាលែងធ្វើដំណើរការទូតលាក់លៀមទៅកាន់ប្រទេសវៀតណាមទៀតហើយនោះ គាត់ក៏បានធ្វើដំណើរទស្សនកិច្ចជាផ្លូវការមកកាន់ក្រុងហាណូយវិញ ។ នេះជាដំណើរទស្សនកិច្ចដំបូងគេបង្អស់ក្នុងចំណោមប្រទេសស្ថាបនិកអាស៊ាន។ ដំណើរការនេះបានបន្តធ្វើរហូតអស់រយៈពេលបីឆ្នាំ ។ បន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ចរបស់លោកលើកទីបីទៅកាន់ប្រទេសវៀតណាម លោកមេបញ្ជាការកងទ័ពឥណ្ឌូនេស៊ីបានថ្លែងថា រដ្ឋការក្រុងហាណូយមិនបានបង្កការគំរាមកំហែងដល់អាស៊ីអាគ្នេយ៍ទេ ហើយគាត់ថ្លែងបន្តថាការឈ្លានពានរបស់វៀតណាមចូលមកកម្ពុជាគឺធ្វើឡើងក្នុងគោលបំណងការពារខ្លួនដើម្បី «រក្សានូវទឹកដី និងប្រជាជនរបស់ខ្លួនពីការវាយប្រហារដោយកម្លាំងប្រដាប់អាវុធរបស់ពួកប៉ុលពតតែប៉ុណ្ណោះ ។ ពីរអាទិត្យក្រោយមក លោកជូស៊ុស វ៉ាណាន់ឌីនាយកមជ្ឈមណ្ឌលសិក្សាយុទ្ធសាស្ត្រ និងកិច្ចការអន្តរជាតិរបស់ប្រទេសឥណ្ឌូនេស៊ី(ជាគ្រឹះស្ថានសាធារណៈ) បានមកចូលរួមក្នុងសិក្ខាសាលារួមគ្នាមួយនៅក្នុងទីក្រុងហាណូយ។ លោកវ៉ាណានឌី បានធ្វើឲ្យអ្នកអង្កេតការណ៍ជាច្រើនរូបមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយគាត់បានធ្វើការកោតសរសើរដល់ «ការប្រយុទ្ធទាមទារឯករាជ្យជាប្រវត្តិសាស្ត្ររបស់វៀតណាម» ហើយគាត់បានផ្តល់ជាអនុសាសន៍ឲ្យមាន«ការសហការជាមួយវៀតណាមប្រសិនបើខាងភាគីវៀតណាមមានបំណងរួមគ្នាស្វែងរកការសម្រុះសម្រួលមួយដើម្បីដោះស្រាយបញ្ហាជម្លោះនៅកម្ពុជា» ។[៩] បន្ទាប់មកប្រទេសវៀតណាមបានធ្វើការស្នើសុំឲ្យមានចំណងការទូតសារជាថ្មីដែលលោករដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូនេស៊ីគឺលោក ម៉ូស្តា គុសុម៉ាតមាជ្យាបានហៅថា៖ «ជាការបោះជំហានដ៏សំខាន់»។ លោករដ្ឋមន្ត្រីរូបនេះក៏បានធ្វើដំណើរទស្សនកិច្ចពីរដងទៅកាន់រដ្ឋធានីម៉ូស្គូដើម្បីពិភាក្សាពីបញ្ហាប្រទេសកម្ពុជាជាមួយនឹងសហភាពសូវៀត អ្នកគាំទ្ររដ្ឋការក្រុងហាណូយ និងក្រុងភ្នំពេញ។ សូម្បីតែលោករដ្ឋមន្ត្រីការបរទេសប្រទេសថៃដែលគាំទ្រប្រទេសចិនក៏បានស្វាគមន៍ចំពោះ«ការវិវត្តថ្មី» នៃតួនាទីរបស់រដ្ឋការក្រុងហាណូយដែរ។[១០]

ការកោតសរសើររបស់លោករដ្ឋមន្ត្រីវ៉ាន់ណាន់ឌីចំពោះ«ការប្រយុទ្ធទាមទារឯករាជ្យ» របស់វៀតណាម គឺគ្រាន់តែសំដៅទៅលើមូលហេតុដូចគ្នានឹងអ្វីដែលប្រទេសឥណ្ឌូនេស៊ីបានធ្វើការ

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread-Michel.qxd 5/11/2011 9:53 AM Page 23



ទាមទារឯករាជ្យពីពួកអាណានិគមហូឡង់តែប៉ុណ្ណោះ ប៉ុន្តែ មិនមែនសំដៅទៅលើការក្រោកឡើងបះបោរប្រឆាំងរបស់ជនជាតិទីម័រខាងកើតទៅនឹងការឈ្លានពានរបស់ឥណ្ឌូនេស៊ីនៅពេលនោះទេ។ នៅឆ្នាំ១៩៨៩ ប្រទេសវៀតណាមបានឆ្លើយតបទៅនឹងការអំពាវនាវរបស់រដ្ឋការក្រុងយ៉ាកាតាឲ្យវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា ប៉ុន្តែ ប្រទេសទីម័រខាងកើតត្រូវរង់ចាំមួយទសវត្សរ៍ទៀតសិនមុននឹងប្រទេសឥណ្ឌូនេស៊ីបញ្ឈប់នូវការឈ្លានពានដ៏សាហាវយង់ឃ្នងនៅទីនោះ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការធ្វើការទូតថ្នាក់តំបន់ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាកម្ពុជាមានការជួយជ្រោមជ្រែងបន្តិចម្តងៗ។ នៅឆ្នាំ១៩៨៥ រដ្ឋការក្រុងហាណូយទាមទារឲ្យប្រទេសចិនបញ្ឈប់ការគំរាមកំហែងរបស់ខ្លួនមកលើប្រទេសវៀតណាមជាមុន មុននឹងការដកកងទ័ពវៀតណាមទាំងស្រុងចេញពីប្រទេសកម្ពុជា។[១១] លោកហេឌិន.រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលីបានធ្វើដំណើរទស្សនកិច្ចនៅក្រុងហាណូយក្នុងខែមីនាឆ្នាំ១៩៨៥ ហើយបានទទួលដឹងពីសំណើរបស់វៀតណាមបន្ថែមទៀត។ សំណើទាំងនេះត្រូវបានលោករដ្ឋមន្ត្រីរូបនេះហៅថាជា«ការរីកចម្រើនដ៏ធំ»។ លោក ហេឌិន បានលើកឡើងថាដំណើរទស្សនកិច្ចរបស់គាត់«បានទទួលជោគជ័យយ៉ាងខ្លាំងហើយលទ្ធផលនេះនឹងលេចចេញជារូបរាងពិតប្រាកដជាក់ជាពុំខាន»។[១២] លោក ម៉ូស្តា រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូនេស៊ីក៏បានឯកភាពថាមាន «ការរីកចម្រើនដ៏ធំ»នៃតួនាទីរបស់រដ្ឋការក្រុងហាណូយពិតប្រាកដមែន។[១៣]

ខណៈពេលធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមលោកហេឌិន ក៏បានជួបលោកហ៊ុន សែន នាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសកម្ពុជាផងដែរ។ កិច្ចជំនួបនេះបានធ្វើឲ្យលោកហេឌិន.ក្លាយទៅជាមេដឹកនាំដំបូងគេក្នុងចំណោមមេដឹកនាំក្នុងតំបន់ដែលបានជួបជាមួយនិងលោកនាយករដ្ឋមន្ត្រីហ៊ុន សែន។ លោក ហ៊ុន សែនបានប្រាប់គាត់ថា«យើងត្រៀមខ្លួនជាស្រេចក្នុងការធ្វើសម្បទានដល់សម្តេចនរោត្តម សីហនុ និងអ្នកដទៃទៀត ប្រសិនបើពួកគេយល់ព្រមចូលរួមជាមួយពួកយើងក្នុងការកំចាត់ពួកប៉ុល ពត»។ ក្រោយមកលោកហ៊ុន សែន បានប្រកាសថាកងទ័ពវៀតណាមមិនស្ថិតនៅក្នុងប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៩៥ទេ ពួកគេនឹងដកចេញទាំងស្រុងនៅក្នុងឆ្នាំ១៩៩០ ឬមុននេះ វាអាស្រ័យទៅលើការព្រមព្រៀងដោះស្រាយជម្លោះនោះ។

ពេលនោះប្រទេសវៀតណាមគ្រាន់តែទាមទារថាធ្វើយ៉ាងណាមិនឲ្យពួកខ្មែរក្រហមត្រឡប់មកកាន់អំណាចវិញប៉ុណ្ណោះ។ ចំណុចនេះមានន័យថាបញ្ហាប្រទេសកម្ពុជាអាចដោះស្រាយ បានត្រឹមតែនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ជាពិសេសគឺដោះស្រាយដោយការឲ្យប្រទេសថៃឈប់ផ្តល់កន្លែងជ្រកកោន និងកន្លែងដឹកជញ្ជូនសម្ភារៈសឹក និងការផ្គត់ផ្គង់ដទៃទៀតមកពីប្រទេសចិន ព្រោះវាបានជួយធ្វើឲ្យពួកខ្មែរក្រហមនៅតែអាចរស់រាន មានជីវិត។ ចំណែកឯប្រទេសវៀតណាមវិញគេអាចដោះស្រាយបានដោយដកកងទ័ពរបស់ខ្លួនដែលនៅសេសសល់ចេញពីប្រទេសកម្ពុជា។ ដូច្នេះការសហការពីខាងភាគីចិនក្នុងការដោះស្រាយបញ្ហាប្រទេសកម្ពុជាលែងមានសារៈសំខាន់ទៀតហើយ។ ដោយមានការគាំទ្រពីអូស្ត្រាលីផងនោះ ប្រទេសឥណ្ឌូនេស៊ីបានជួយរៀបចំវេទិកាក្នុងការស្វែងរកដំណោះស្រាយថ្នាក់តំបន់សំរាប់បញ្ហាប្រទេសកម្ពុជា។

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Michel.qxd 5/11/2011 9:53 AM Page 24



នៅថ្ងៃទី១០ខែមេសាឆ្នាំ១៩៨៦ព្រឹត្តិបត្តិសេដ្ឋកិច្ចអាស៊ីចុងបូព៌ាបានរាយការណ៍ថា នៅក្នុងខែមិថុនា រដ្ឋមន្ត្រីអាស៊ានទាំងឡាយនឹងសម្រេចជាចុងក្រោយនូវ«ផែនទីបង្ហាញផ្លូវដ៏លំអិតសំរាប់ដោះស្រាយបញ្ហាកម្ពុជា»៖

> ផែនទីបង្ហាញផ្លូវដែលបានមកពីការប្រជុំបិទទ្វារបានព្យាយាមបំពេញនូវការទាមទាររបស់វៀតណាមដែលចង់ឲ្យមានការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាត្រូវធ្វើឡើងស្របគ្នាជាមួយនឹងការបញ្ឈប់ការផ្គត់ផ្គង់សព្វាវុធរបស់ចិនទៅដល់ក្រុមចលនាត-ស៊ូខ្មែរ ហើយបន្ទាប់មកត្រូវដាក់កងកម្លាំងរក្សាសន្តិភាពអន្តរជាតិឲ្យឈរជើងនៅតាមព្រំដែនដីគោក និងសមុទ្រ ។ ព្រំដែនសមុទ្រត្រូវបានគេកំណត់ដើម្បីធានាថាវៀតណាម និងចិនមិនអាចបន្តការផ្គត់ផ្គង់នៅខណៈពេលដែលផ្លូវគោកជាច្រើនពីប្រទេសថៃត្រូវបិទបន្ទាប់ពីការដោះស្រាយជម្លោះបានជោគជ័យ ។

ប្រទេសចិន និងរដ្ឋាភិបាលចម្រុះខ្មែរក្រហមបានបដិសេធនូវគំនិតផ្តួចផ្តើមនេះ។ ការប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ខែមិថុនា ឆ្នាំ១៩៨៦ នៅម៉ានីលពុំបានពិភាក្សាលើបញ្ហានេះទេ។ ប៉ុន្តែលោករដ្ឋមន្ត្រី ហេឌិន បានលើកពីបញ្ហាខ្មែរក្រហម។ នៅឯកិច្ចប្រជុំទីក្រុងម៉ានីលគាត់បានធ្វើនូវរឿងថ្មីមួយទៀត នៅពេលគាត់បានស្នើឲ្យបង្កើតនូវសាលាក្តីអន្តរជាតិកាត់ទោសបណ្តាមេដឹកនាំប៉ុលពតពីបទប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ ដោយការទទួលយកនូវការស្នើរបស់លោក ហ្គ្រេហ្គោរី ស្តេនថុន(Gregory Stanton) ដែលជាមេធាវីអន្តរជាតិម្នាក់ស្ថិតក្នុងដំណើរទស្សនកិច្ចទៅប្រទេសកម្ពុជានៅពេលនោះនោះ លោក ហេឌិន បានក្លាយទៅជារដ្ឋបុរសដំបូងគេដែលគាំទ្រឲ្យពួកមេដឹកនាំខ្មែរក្រហមត្រូវប្រឈមចំពោះមុខច្បាប់នូវទង្វើរបស់ពួកគេ ពោលគំនិតនេះបានផ្តួចផ្តើមតាំងពីពីរទសវត្សរ៍មុនដំណើរការសាលាក្តីកូនកាត់ កាត់ទោសខ្មែរក្រហមរបស់អង្គការសហប្រជាជាតិ និងកម្ពុជា បានប្រព្រឹត្តទៅនៅឆ្នាំ២០០៦ទៅទៀត ។

ទាក់ទងនឹងបញ្ហាប្រទេសកម្ពុជាដែលបានរៀបរាប់មកនេះ ពួកមេដឹកនាំមហាអំណាចមានគំនិតមិនស្របគ្នានឹងមេដឹកនាំនៅក្នុងតំបន់នោះទេ។ លោករដ្ឋលេខាធិការរបស់អាមេរិក ចច ស្ហូល (George Shulz) បានបដិសេធមិនគាំទ្រគំនិតបង្កើតសាលាក្តីខ្មែរក្រហមនេះទេ។ ឯប្រទេសចិនវិញក៏មិនគាំទ្រដែរ។ ចំពោះលោក បប់ ហរខឹ (Bob Hawke) នាយករដ្ឋមន្ត្រីប្រទេសអូស្ត្រាលីនិយមអាមេរិករូបនេះក៏បានព្យាយាមដកខ្លួនឲ្យឆ្ងាយចេញពីការស្នើដ៏ត្រឹមត្រូវរបស់រដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្លួនផងដែរ។ ប៉ុន្តែ ជាគោលការណ៍លោករដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ីបានគាំទ្រដល់សំណើរបស់លោកHayden ភ្លាមៗ ហើយពីរបីអាទិត្យក្រោយមក លោករដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូនេស៊ីក៏បានយល់ស្របផងដែរ.។[១៤] មួយឆ្នាំក្រោយមក លោកម៉ូស្តា ជាថ្មីម្តងទៀតបានធ្វើការគាំទ្រជាសាធារណៈដល់សំណើកាត់ទោសប៉ុល ពតនៅតុលាការពិភពលោកចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលពួកគេបានប្រព្រឹត្ត ។[១៥] សូម្បីតែសម្តេចនរោត្តម សីហនុក៏បានដកខ្លួនមួយរយៈចេញពីរដ្ឋាភិបាលចម្រុះខ្មែរក្រហមដែរ។ បន្ទាប់មក ទ្រង់បានជួបជាមួយនឹងលោក ហ៊ុន សែនជាលើកដំបូងនៅខែធ្នូ ឆ្នាំ ១៩៨៧

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 25



ហើយបានទទួលយកសំណើរបស់លោក ហ៊ុន សែន ដែលសុំឲ្យទ្រង់ដកអាវុធពីខ្មែរក្រហមទៅជូនរដ្ឋ-ការក្រុងប៉េកាំងវិញទៅៗ ប៉ុន្តែ ចិនបដិសេធសំណើនោះ ហើយសម្តេច សីហនុ ក៏បានលុបចោលនូវការចរចាបន្ទាប់ទៀតជាមួយនឹងលោកហ៊ុន សែនៗ

ប៉ុន្តែ ប្រទេសតណ្ហូនេស៊ីនៅតែបន្តគំនិតផ្តួចផ្តើមទំនាក់ទំនងការទូតថ្នាក់តំបន់ស្តីពីបញ្ហាប្រទេសកម្ពុជាខ្លាំងឡើងៗថែមទៀតៗ នៅខែកក្កដា ឆ្នាំ ១៩៨៨ កិច្ចប្រជុំយ៉ាកាតាក្រៅផ្លូវការជាលើកដំបូងបានធ្វើនៅរមណីយដ្ឋានលើកំពូលភ្នំផ្កា ឯក្រុងបូហ្គ័រ(Bogor) ដែលចូលរួមដោយអ្នកតំណាងមកពីបណ្តាប្រទេសអាស៊ាន និងប្រទេសនៅតណ្ហូចិន រួមទាំងភាគីខ្មែរទាំងអស់ផងដែរៗ ការប្រជុំនេះបានជួបប្រទះនឹងបញ្ហាលំបាកដ៏ធំ ពោលគឺការបដិសេធពីភាគីខ្មែរក្នុងការជួបចរចាទល់មុខគ្នាៗ ភាគីនីមួយៗនៅតែទទូចទាម-ទារចូលរួមចរចាតែជាមួយនឹងពួកដែលមានបរទេសគាំទ្រពីក្រោយតែប៉ុណ្ណោះៗ ប្រទេសតណ្ហូនេស៊ីបានជម្នះនូវបញ្ហាទាំងនោះប្រកបដោយភាពវ័យឆ្លាត និងមានជំនាញ ដោយឲ្យរាល់ភាគីខ្មែរដំបូងឡើយជួបនឹងអ្នកគាំទ្រក្រុមនីមួយៗមកពីបណ្តាប្រទេសអាស៊ីអាគ្នេយ៍ដែលចូលរួមក្នុងសន្និសីទនោះដែរ ៗ

«សេចក្តីថ្លែងការណ៍គាំទ្ររួម» ពីកិច្ចប្រជុំនោះធ្វើឡើងដោយលោក អាលី អាឡាតាស រដ្ឋមន្ត្រីក្រសួងការបរទេសតណ្ហូនេស៊ីថ្មី បានសង្កត់ធ្ងន់ទៅលើបញ្ហាពីរដែលលោក Hayden បានកំណត់÷ ១) ការដកកងទ័ពវៀតណាម(សន្យាថានឹងធ្វើនៅឆ្នាំ១៩៩០) និង ២) ការរារាំង«មិនឲ្យមានការកើតឡើងវិញនូវគោលនយោបាយ និងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៃរបបប៉ុលពត» ៗ[១៦] នៅខែមេសា ឆ្នាំ១៩៨៩ វៀតណាមបានសម្រេចដកកងទ័ពមុនការគ្រោងទុក ពោលគឺពួកគេបានដកកងទ័ពរបស់ពួកគេចេញពីប្រទេសកម្ពុជានៅខែកញ្ញាៗ នៅខែបន្ទាប់ សម្តេច នរោត្តម សីហនុ និងលោក ហ៊ុន សែន ក៏បានជួបគ្នាសារជាថ្មីម្តងទៀតនៅយ៉ាកាតា ៗ នៅក្នុងជំនួបនោះពួកគេបានធ្វើកិច្ចព្រមព្រៀងទូទៅមួយ ហើយសម្តេចនរោត្តម សីហនុបានមានព្រះឱង្ការថា ទ្រង់ត្រៀមខ្លួនជាស្រេចក្នុងការធ្វើកិច្ចសហការដោយពុំចាំបាច់មានពួកខ្មែរក្រហម ប្រសិនបើពួកគេមិនគោរពតាមនោះៗ[១៧] ប៉ុន្តែទ្រង់បានបដិសេធនូវការសន្យានោះភ្លាមៗបន្ទាប់ពីទ្រង់ចាកចេញពីយ៉ាកាតាៗ

ការប្រជុំក្រៅផ្លូវការនៅយ៉ាកាតាលើកទី៣ នៅខែកុម្ភៈ ឆ្នាំ១៩៩០ បានបរាជ័យដោយសារខ្មែរក្រហមបដិសេធមិនប្រើប្រាស់ពាក្យថា «ប្រល័យពូជសាសន៍» នៅក្នុងសេចក្តីថ្លែងការណ៍ផ្លូវការ (communiqué)ចុងក្រោយៗ បើទោះបីជាពាក្យនេះមាននៅក្នុងសេចក្តីថ្លែងការណ៍មុនៗក៏ដោយ ក៏ឥឡូវនេះ ពួកខ្មែរក្រហមបានបដិសេធក្នុងការដាក់បញ្ចូលពាក្យនេះ ដោយទទូចឲ្យលើកឡើងពី «ពួកអន្តោប្រវេសន៍វៀតណាម» នៅក្នុងប្រទេសកម្ពុជាវិញ ប៉ុន្តែ ត្រូវបានលោកហ៊ុន សែន និងលោក ង្វៀងគឹថាច់ (Nguyen Co Thach) រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមជំទាស់ៗ នៅពេលនោះ លោកហ្គារ៉េត អ៊ីវ៉ាន់ (Gareth Evans) រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលីបានស្នើឲ្យដាក់សញ្ញាសម្គាល់ជារូបផ្កាយនៅក្បែរឃ្លានីមួយៗដែលពុំទាន់មានការយល់ស្របគ្នា ហើយសរសេរជាការពន្យល់ថាពាក្យទាំងនោះពុំទាន់មានការឯកភាពគ្នានៅឡើយទេៗ លោកហ៊ុន សែន និងលោក ថាច់ បានយល់ស្របចំពោះការសម្របសម្រួលនេះៗ ប៉ុន្តែ ពួកខ្មែរក្រហមបានបដិសេធ ហើយការពិភាក្សាចរចាគ្នាក៏បានបញ្ចប់ត្រឹមតែប៉ុណ្ណឹងៗ[១៨] សម្តេច នរោត្តម សីហនុនិងដៃគូប្រឆាំងនឹងពួកកុំម្មុយនីស្តរបស់ទ្រង់គឺលោកសឺន សាន

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 26



នៅតែបដិសេធមិនព្រមផ្តាច់ខ្លួនចេញពីពួកខ្មែរក្រហមឡើយ។

ប៉ុន្តែ នៅខណៈពេលនោះស្ថានការណ៍នៅក្នុងតំបន់ក៏កំពុងតែមានការប្រែប្រួលដែរ។ គោលនយោបាយរបស់ប្រទេសថៃដែលជា«ប្រទេសប្រឈមដោយផ្ទាល់(font–line state)» ភាគច្រើនទទួលការគំរាមកំហែងពីការដួលរំលំរបបប៉ុលពតដែលធ្វើឡើងដោយរដ្ឋការក្រុងហាណូយក៏បានផ្លាស់ប្តូរទៅតាមទិសដែលដៅឲ្យដោយប្រទេសឥណ្ឌូនេស៊ី និងអូស្ត្រាលីដែរ។ លោក ឆាតិឆៃ ឈុនហាវ៉ាន់ នាយករដ្ឋមន្ត្រីថៃដំបូងដែលជាប់ដោយការបោះឆ្នោតតាំងពីឆ្នាំ ១៩៧៦មកនោះ បានឈ្នះឆ្នោតចូលកាន់តំណែងនៅក្នុងឆ្នាំ១៩៨៨ ហើយបានបន្តគោលនយោបាយថ្មីមកលើប្រទេសកម្ពុជា រហូតដល់ពួកយោធាផ្តាច់ការបានទម្លាក់រដ្ឋាភិបាលរយៈពេលខ្លីរបស់គាត់ នៅឆ្នាំ១៩៩១។ នៅអំឡុងពេលបីឆ្នាំនេះ ដោយមើលឃើញពីប្រយោជន៍ដែលបានមកពីការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាលឿនជាងការគ្រោងទុកនោះ រដ្ឋការក្រុងបាងកកបានបង្កើតទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយនឹងរដ្ឋការក្រុងហាណូយ និងភ្នំពេញដោយសង្ឃឹមថានឹងធ្វើឲ្យឥណ្ឌូចិនត្រឡប់ពី «សមរភូមិសង្គ្រាមទៅជាកន្លែងធ្វើជំនួញដូរដូរនឹងគ្នាវិញ»។ នៅអាស៊ីអាគ្នេយ៍បញ្ហាកម្ពុជាគឺជារឿងរ៉ាវដ៏ធំដែលធ្វើឲ្យតំបន់ទាំងមូលមានការបែកខ្ញែក ហើយក៏ធ្វើឲ្យមានការខិតខំបង្កើតឲ្យមានការជួយជ្រោមជ្រែងពីក្នុងតំបន់ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាកម្ពុជាផងដែរ។[១៩] ការសម្រេចរួមគ្នានៅក្នុងការប្រជុំជាច្រើននៅឥណ្ឌូនេស៊ី និងកន្លែងផ្សេងទៀតជាធម្មតាមានទំនោរគាំទ្រដំណោះស្រាយដែលទាត់ចោលនូវការដាក់ពង្រាយកងទ័ពវៀតណាមនៅក្នុងប្រទេសកម្ពុជា និងពួកខ្មែរក្រហម(នេះជាអ្វីដែលរដ្ឋការក្រុងហាណូយស្វាគមន៍)។

ផែនការឆ្នាំ១៩៩១ របស់អង្គការសហប្រជាជាតិដែលជាផែនការចុងក្រោយនោះនៅតែផ្តោតការយកចិត្តទុកដាក់ដល់ការជំទាស់របស់ចិននិងសហរដ្ឋអាមេរិកដែលប្រឆាំងទៅនឹងការទាត់ចោលពួកខ្មែរក្រហម ប៉ុន្តែប្រទេសឥណ្ឌូនេស៊ីរួមជាមួយនឹងប្រទេសអូស្ត្រាលី និងថៃផងនោះ បានព្យាយាមបំពេញនូវការងារការទូតដ៏លំបាកនេះដើម្បីស្វះស្វែងរកនូវការសម្រុះសម្រួលថ្នាក់តំបន់ និងការព្រមព្រៀងគ្នាដោះស្រាយបញ្ហាកម្ពុជាប្រកបដោយប្រសិទ្ធភាព។ បើទោះបីជាមានការបំពេញតួនាទីខុសគ្នាក្តី ក៏មត៌កដ៏សំខាន់របស់ឥណ្ឌូនេស៊ីបានបន្តរហូតមកដល់ទសវត្សរ៍ឆ្នាំ៩០ នៅពេលដែលលោកបេន្នី បានបំពេញតួនាទីដ៏ឯករាជ្យជាមន្ត្រីរបស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា។ តួនាទីទាំងនោះមានរៀបរាប់យ៉ាងច្បាស់នៅក្នុងសៀវភៅកំណត់ត្រាជាប្រវត្តិសាស្ត្ររបស់គាត់ដែលមាននៅក្នុងដៃរបស់អស់លោក-លោកស្រី។ ខ្ញុំសង្ឃឹមថាការយកចិត្តទុកដាក់ពីថ្នាក់តំបន់ចំពោះសន្តិភាព និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជាជាចុងក្រោយ នឹងជម្នះលើផលប៉ះពាល់ទាំងឡាយដែលបណ្តាលមកពីរបបប្រល័យពូជសាសន៍ និងសកម្មភាពនយោបាយរបស់ពួកមហាអំណាច។

បើទោះបីជាព្រះវិហារនៅអាលឥសានត្រូវគេបំផ្លាញខ្ទេចខ្ទីហើយក្តី ព្រះវិហារនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យគេបានយល់ដឹងពីប្រទេសកម្ពុជា និងសហគមន៍ជនជាតិភាគតិចចាមនៅកម្ពុជា។ គឺនៅក្នុងព្រះវិហារនេះហើយដែលអ្នកសារព័ត៌មានដ៏សំខាន់របស់ឥណ្ឌូនេស៊ីដំបូង បានជួបជាមួយនឹងមេដឹកនាំសាសនិកជនឥស្លាមដែលបានរួចពីសេចក្តីស្លាប់។ នៅទីនោះហើយដែលជនជាតិចាមបានចាប់ផ្តើមបញ្ចេញសម្លេងឲ្យពិភពឥស្លាមបានឮ ហើយជួយជម្រុញឲ្យមានការផ្លាស់ប្តូរកា-

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 27



*រយល់ដឹងនៅក្នុងតំបន់ និងចុងក្រោយនៅលើពិភពលោកទាំងមូលអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ខ្មែរក្រហមៗ «ពន្លឺនៃសេចក្តីករុណា» អាចបែងចាំងបានជាលើកចុងក្រោយតែក្នុងកំឡុងទសវត្សរ៍ឆ្នាំ៨០ប៉ុណ្ណោះៗ ចំណែកឯព្រះវិហារថ្មីមានពន្លឺភ្លឺផ្លេកដែលគេសាងសង់ជំនួស និងដាក់ឈ្មោះដូចព្រះវិហារចាស់ នឹងជួយសាសនិកជនឥស្លាមនៅកម្ពុជាយ៉ាងដូចម្តេចនោះ គឺជាសំណួរមួយផ្សេងទៀតៗ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមចំណែករបស់មនុស្សជាច្រើនដូចជាលោកបេន្នី វីដ្យូណូ (Benny Widyono) រួមទាំងការខំប្រឹងប្រែងរបស់តួអង្គសំខាន់ៗនៅក្នុងតំបន់ និងប្រជាជនកម្ពុជាដោយផ្ទាល់ផងដែរ ឥឡូវនេះប្រទេសរបស់ពួកគេបានទ្រោលបំភ្លឺដោយពន្លឺសេចក្តីករុណារបស់ខ្លួនៗ*

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 28



## កំណត់ចំណាំជំពូកបុព្វកថារបស់លោក បិន ឃៀរនិន

[១] *សូមមើលស្នាដៃ លោក អេនថូនី បានេតនិងចនគីលហ្គី, សម័យកាលក្រោយសង្គ្រាមៈការតស៊ូរបស់ប្រទេសកម្ពុជា និងវៀតណាម,បោះពុម្ពនៅទីក្រុងឡុង, រោងពុម្ព* New Statesman, *ឆ្នាំ១៩៨២ ។*

[២] *លោក សូរិយា ស៊ីម ដ៏មានសមានចិត្តល្អបានជួយទៅសួរបញ្ជាក់ហាគីមជំនួសខ្ញុំ។ ការសន្ទនាផ្ទាល់ខ្លួននៅថ្ងៃទី១៦ និង ១៧ខែមករាឆ្នាំ២០០៧ ។*

[៣] *សាបាម ស្យាគៀន* «Resepnya: Pangan, Agama dan Seni Budaya (Asal Tetap Aman), » *Sinar Harapan,* n.d.*ឆ្នាំ ១៩៨១ ។*

[៤] *សូមមើលឧទាហរណ៍ បិនឃៀនិន, «តើអ្វីដែលយើងបានរៀនសូត្រពីសាសនិកជនឥស្លាមឥណ្ឌូនេស៊ី» នៅក្នុងសៀវភៅដឹកនាំផ្សៀងផ្ទាត់ដោយលោក* T.N. Srinavasan, ed., *អនាគតអាណាចក្រនិយម, ញូដែល្ហី, អកស្វឺត, ឆ្នាំ២០០៦, ទំព័រ១៨១-៨៥ ។*

[៥] *សូមមើលឧទាហរណ៍ដេនិត ស្មៀល,សង្គ្រាមពីខាងក្នុងៈរឿងរបស់ថិមបូ, ទស្សនាវដ្ដីឯករាជ្យមួយនៅប្រទេសឥណ្ឌូនេស៊ីសម័យស៊ូហាតូ(យ៉ាកាតា,* Equinox, *២០០៥)។ សារព័ត៌មានស៊ីណាហារាប៉ាន់បានបង្កើតឡើងវិញនៅក្នុងឆ្នាំ១៩៨៧ដោយយកឈ្មោះថា ស៊ូរាកេមបារូន។*

[៦] *ព្រឹត្តិបត្រសេដ្ឋកិច្ចអាស៊ីចុងបូព៌ា, សៀវភៅកត់ហេតុប្រចាំឆ្នាំនៅអាស៊ីឆ្នាំ១៩៨១, (បោះពុម្ពនៅក្រុងហុងកុង ឆ្នាំ១៩៨១), ទំព័រលេខ១៩១*

[៧] *ណាយ៉ានចាន់ដា, បងប្អូនដែលជាសត្រូវ(បោះពុម្ពនៅក្រុងញូយ៉កឆ្នាំ១៩៨៦)ទំព័រ ៣៩៣។*

[៨] *ម៉ារៀន វីគីនសុន, «កម្ពុជា: សញ្ញានៃការផ្លាស់ប្តូរខ្លះៗ», ព្រឹត្តិបត្រ National Times,(បោះពុម្ពនៅអូស្ត្រាលី) ចេញផ្សាយពីថ្ងៃទី៦-១២ខែមេសាឆ្នាំ១៩៨៤, ទំព័រ១២-១៧,* at ១៣។

[៩] *Age (បោះពុម្ពនៅម៉ែលប៊ន),ថ្ងៃទី១៦ខែមីនាឆ្នាំ១៩៨៤, វីគីនសុន, «កម្ពុជាៈសញ្ញានៃការផ្លាស់ប្តូរខ្លះៗ»,ព្រឹត្តិបត្រ National Time.ចេញផ្សាយពីថ្ងៃទី៦-១២ខែមេសាឆ្នាំ១៩៨៤។*

[១០] *Age, ថ្ងៃទី១៦, ទី១៩ និង ថ្ងៃទី២៧ខែមីនា ឆ្នាំ១៩៨៤ ។*

[១១] *រដ្ឋការក្រុងហាណូយបានបញ្ចេញនូវគោលនយោបាយថ្មីរបស់ខ្លួននៅក្នុងឆ្នាំ១៩៨៤ អត្ថបទចុះផ្សាយនៅសារព័ត៌-មានញាន់ដាន(Nhan Dan)ខែវិច្ឆកា បានរៀបរាប់ថាវៀតណាមអាចនឹងដកកងទ័ពចេញពីប្រទេសកម្ពុជា«នៅពេលការគំរាមកំហែងរបស់ប្រទេសចិន និងគ្រោះថ្នាក់បណ្តាលមកពីការវិលត្រឡប់មកកាន់អំណាចវិញនៃរបបប៉ុល ពតលែងមានតទៅទៀតនិងនៅពេលដែលសន្តិសុខរបស់ប្រទេសកម្ពុជាត្រូវបានធានាយ៉ាងពេញលេញ» ប៉ុន្តែ អត្ថបទនោះក៏បានបង្ហាញនូវការថ្លែងការណ៍របស់រដ្ឋការក្រុងហាណូយថា«បោះបង់ពួកខ្មែរក្រហមដែលនៅសេសសល់ចោលជាជាងការអំពាវនាវឲ្យវៀតណាមដកកងទ័ពចេញដោយឯកតោភាគីពីកម្ពុជាគឺជាតម្រូវការចាំបាច់ និងបន្ទាន់ក្នុងការស្វែងរកសន្តិភាពនៅក្នុងតំបន់» ។* Age *(បោះពុម្ពនៅម៉ែលប៊ន), ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៨៤។*

[១២] *បិន ឃៀនិន «កម្ពុជាៈហេឌិនពិតជាត្រូវមែន»ព្រឹត្តិបត្រ Australian Society, វ៉ុល៤ លេខ២៨ ខែសីហា ឆ្នាំ១៩៨៥, ទំព័រ២០-២៣ ។*

[១៣] *Age ថ្ងៃទី២១ខែមីនាឆ្នាំ១៩៨៥ ។*

Chapter0 Introdution:Correct Osbone 180 x 260 350 pages proofread Rachel.qxd 5/11/2011 9:53 AM Page 29



[១៤] *Sydney Morning Herald* ថ្ងៃទី២៧ មិថុនា ឆ្នាំ១៩៨៧ និងសន្និសីទសារព័ត៌មានរបស់ម៉ូស្តា នៅទីក្រុងយ៉ាកាតា ថ្ងៃទី ៨ សីហា ឆ្នាំ១៩៨៦ រាយការណ៍នៅក្នុងសារព័ត៌មាន *Indonesia Times*។

[១៥] ព្រឹត្តិបត្រ *Christian Science Monitor,* ថ្ងៃទី១៧មិថុនាឆ្នាំ១៩៨៧ ប្រជាជនកម្ពុជាចំនួន២.០០០នាក់ដែលរស់នៅបរទេសបានចុះហត្ថលេខាលើពាក្យបណ្ដឹងហើយបញ្ជូនទៅលោក បប់ ហរខឹ (Bob Hawke)នាយករដ្ឋមន្ត្រីអូស្ត្រាលី សុំឲ្យចាត់វិធានការណ៍នាំប៉ុល ពតទៅកាត់ទោសនៅក្នុងតុលាការពិភពលោក(ព្រឹត្តិបត្រសេដ្ឋកិច្ចអាស៊ីចុងបូព៌ា ចេញផ្សាយថ្ងៃទី១៤ខែកក្កដាឆ្នាំ១៩៨៨) លោក ហរខឹ បានបដិសេធ ប៉ុន្តែលោកអេនឌ្រូ ភីខក់មេដឹកនាំបក្សប្រឆាំងរួមនិងផ្នែកគណកម្មការអ្នកច្បាប់អន្តរជាតិអូស្ត្រាលីបានគាំទ្រនូវគំនិតនេះ។

[១៦] ព្រឹត្តិបត្រសេដ្ឋកិច្ចអាស៊ីចុងបូព៌ា ចេញផ្សាយថ្ងៃទី១១ខែសីហាឆ្នាំ១៩៨៨, ទំព័រទី២៩។

[១៧] «សម្ដេចនរោត្តមសីហនុទ្រង់យាងត្រឡប់មកធ្វើជាប្រមុខរដ្ឋប្រទេសកម្ពុជា»,ហើយ «បានធ្វើសកម្មភាពទាត់ចោលពួកខ្មែរក្រហម» *Sydney Morning Herald* ថ្ងៃទី៣និង៤ឧសភាឆ្នាំ១៩៨៩។

[១៨] វ៉យអេក្លេស្តុន «ផែនការរបស់លោក អ៊ីវ៉ាន់ជាប់គាំងដោយសារការប្រើប្រាស់ពាក្យមិនឯកភាពគ្នា», *Australian,* ផ្សាយពីថ្ងៃទី២ខែមីនា ឆ្នាំ១៩៩០។

[១៩] ដើម្បីយល់ដឹងពីចំណាប់អារម្មណ៍នៅក្នុងតំបន់ចំពោះការតស៊ូដាទូទៅក្រោយសង្គ្រាមប្រឆាំងនឹងរបបអាណានិគមនោះសូមមើលបិនឃៀនិន «អាស៊ាន និងឥណ្ឌូចិន៖ព្រឹត្តិការណ៍គួរឲ្យព្រួយបារម្ភនៅអាស៊ីត្រូវបានបើកកកាយ», *Inside Asia 5*(ចេញផ្សាយខែកញ្ញា និង តុលាឆ្នាំ១៩៨៥), ទំព័រ១៧-១៩។